ni Céline, ni . . . . . et ni . . . et ni Nagez horizontalement à travers ses payois, ses dialectes, son argot.

C'est une méchante réponse pour ceux qui nourrissent l'ambition de parler une langue universelle. Au Congrès de Vienne, Metternich parlait français et à Versailles en 1919, les vaincus martelaient respectueusement la langue des vainqueurs. A Yalta et à Postdam, l'anglais nous évinça. La politique s'en mêlait certes. Elle ne suffira pas à rendre le terrain perdu.

Si l'internationalisme n'est pas le fait de tout le monde, il est un fait que nul ne saurait contester : ce serait bien mal gérer le capital-temps de notre jeunesse que de lui faire perdre des millions d'heures dans l'étude trop respectueuse des particularismes accumulés depuis que Malherbe vint.

Enfin, si l'on n'y veille, il risque de se creuser un fosse entre la langue traditionnelle, figee dans ses infinies nuances, et la langue usuelle, en proie aux tentations de l'argot ou du barbarisme.

Ne croyons pas le drapeau menacé parce qu'il est question d'alleger l'orthographe. Ce n'est pas le français phonetique, fils bâtard de la radio et de la télévision, qui menace notre culture. Il ne s'agit pas d'ériger la tyrannie de l'oreille.

Il s'agit d'épurer une langue et de gagner du temps. Une langue vivante peut et doit changer.

L'orthographe (pour être logique et correct, il faudrait d'ailleurs dire: orthographie . . . ) que l'on applique aujourd'hui de façon plus ou moins sourcilleuse n'est pas une richesse d'âge immémorial : c'est une codification qui s'est imposée avec l'extension de l'enseignement primaire. En bref, c'est la fille du XIX° siècle.

Tant que la langue écrite était l'apanage de l'aristocratie et de la bourgeoisie, celles-ci, plus soucieuses d'élégance et de correction grammaticale que de precision orthographique, témoignaient à son égard d'une joyeuse fantaisie. On ecrit alors dous pour doux, innocen, enfan, parlemen, long-temps ou longtemps et jusqu'à la veille de 1914, « le Journal des Débats» et la «Revue des deux Mondes» qui n'étaient pas des repaires d'illettrés, maintinrent cette orthographe-là.

## LA FILLE DU XIXè SIECLE

Parallèlement, toutefois, plusieurs projets de réforme virent le jour. Dès 1835, l'Académie Française avait donné l'exemple d'une adaptation raisonnable en supprimant l'un des usages les plus enracinés chez les écrivains, la graphie oi pour une prononciation ai, comme dans « François avoit de la monnoie ».
Et la septième édition de son dictionnaire, en 1878, introduisit plusieurs modifications orthographiques.

A la fin du siècle, et dans les premières années de celui-ci, plusieurs savants éminents, parmi lesquels des philologues aussi illustres que Gaston Paris, Darmesteter, Clédat, Gréard, Ferdinand Brunot, des écrivains tels qu'Emile Faguet, Rémy de Gourmont, Anatole France menèrent campagne pour une large réforme de l'orthographe et de la grammaire. Ils aboutirent à un premier résultat : l'arrêté du 26 Février 1901.

C'était un arrêté « de tolérance » . « La plus grande obscurité, déclarait-il, règnant dans les règles et les exceptions enseignées dans les grammaires, on tolèrera . . . .» Suivait une longue liste de tolérances portant sur le pluriel des noms propres de personnes, le pluriel de mots étrangers, l'accord de l'adjectif qualificatif avec plusieurs noms de genres différents, l'accord des adjectifs nu, feue, demi ( permettant par exemple, ce qu'on interdisait à l'auteur de ces lignes sur les bancs de l'école : une demie heure, feue la reine. . . ), les participes passés invariables, les adjectifs numéraux, l'accord du verbe précédé de plusieurs sujets non unis par la conjonction et, l'acccord du participe présent et de nombreux autres problèmes hérissant l'enseignement du français de redoutes, demi-lunes et caponnières d'approche quasiment impossible.

Restait à effectuer une réforme en profondeur.

## L'USAGE ET L'ABUS

L'arrêté de 1901 ne visait, apparemment, qu'à éliminer des sujets de litiges en admettant des variations incorrectes au départ mais consacrées par l'usage. Mais une réforme en profondeur ne risquait-elle pas de miner la langue et d'introduire l'abus dans les fourgons de l'usage ?

Quand on évoque - devant ceux qui supportent la discussion - une réforme possible de l'orthographe, bien des gens s'imaginent que cette réforme consistera à permettre d'écrire le français de la façon suivante :

« Mètre korbo dan zun arbre perché Tené dans son bek un fromaj . . .»

Mais depuis le projet Dauzat en 1940, la plupart des réformateurs estiment que la modération est la meilleure garantie d'efficacité. « Partant de points de vue différents, déclare le rapport général de la commission ministérielle d'études orthographiques, étymologie pour Dauzat, histoire de l'orthographie pour Beaulieux, points communs des différents projets pour d'autres, tous les réformateurs actuels se contentent de chercher une solution pratique à des problèmes urgents ».

Telle est également la position de ce rapport général, qu'on peut appeler le « rapport Beslais », du nom du directeur général honoraire de l'enseignement du 1er degré qui en a constitué le dossier depuis 1960.

Ce rapport porte sur dix points

I.— Lettres grecques. II.— X final. III.— Consonnes doubles. IV.— Consonnes parasites. V.— Notation du son S ( S, Z, C, etc. . . ). VI — Notation de son G ( G et J ). VII.— Mots composés. VIII.— Signes auxiliaires. IX.— Notations du son an ( an ou en ) X.— Orthographe de règles.

Ce n'est pas trahir M. Beslais que d'assurer qu'on ne trouve rien de subversif dans son rapport. Que perdrions-nous, par exemple, avec les lettres grecques subsistant dans certains mots? Rume n'est-il pas aussi clair que rhume ? Et les Champs Elysées seront-ils moins français ?

Fini aussi de chantonner les sept cas de pluriel en oux, caillou. chou, genou, hibou . . . Depuis 1908, l'Académie Française les avait condamnés mais eussiez-vous écrit : des chous? Et pourquoi maintenir l'x de paix, d'époux, de noix, de croix, puisqu'il se transforme en s dans les noms dérivés : paisible, épouse, noisette, croiser ? De même, l'on écrirait jalous, heureus, faus . . .

L'une des grosses affaires de ce projet de réforme, ce sera le point des consonnes redoublées. Pourquoi une sotte a-t-elle droit à un t de plus qu'une idiote ? Pourquoi persifler et siffler? Mamelle et mammifère? Homme et homicide ? annuler et nullité ? .

On n'épuiserait pas en cent pages la liste des bizarreries formées par les consonnes doubles. Supprimer celles-ci dans leur totalité ? C'est la brèche ouverte à la confusion : « Je mourais » indiquerait indiféremment l'imparfait et le conditionnel. Occident, occiput, et occire seraient défigurés

Devant ce problème « le plus terrible de la langue française », assurait Faguet, la Commission Beslais s'est armée de prudence. Elle propose d'écrire toujours homme et femme, irritable et illisible, eu égard à l'histoire de la formation de ces mots; mais elle juge qu'on peut écrire barique, colier, charette, mamifère, énemi, térible, ofense, alègre, etc . .

Ne feront exception que l's double à sonorité sifflante entre voyelles, comme dans passion, tasse, moisson, le double « r » de quelques verbes irréguliers, permettant de distinguer entre le futur et le conditionnel ou l'imparfait et le conditionnel, les doubles consonnes ne prononçant séparément, comme ac-cent, ac-cident, ac-cepter, les consonnes doubles déterminées par la rencontre du préfixe in avec la consonne initiale du radical, comme dans illisible ou irrésistible, enfin la consonne double permettant une différenciation entre des homonymes : une arête, arrêta, sa parole.

L'on mettra fin au désordre des adverbes en ament et ement, qui se prononcent tous ament en les écrivant tous en ament. C'est solanèlement que vous conduirez votre fiancée à l'autel et c'est pruadament que vous conduirez votre voiture, ayant bien évité de boire abondament.

## EN RETARD SUR LE PORTUGAL?

Il serait vain de prétendre que cet essai de réforme est étranger à des considérations phonétiques. On le voit bien dans le déblayage opéré sur les consonnes parasites. Si la commission propose douter, prontitude, sculteur et caoutchou, c'est parce que les lettres supprimées ne se prononcent pas. Et si elle maintient présomption et rédemption, de formation pourtant analogue à celle de dompter et promptitude, c'est que ces mots se prononcent encore tels qu'ils s'écrivent

Pareillement, relais, fonds, legs et mots devraient perdre leurs s terminaux. Mais on est surpris de voir que respect, suspect, instinct, doigt, poids, pouls, puits, temps et corps continueraient à s'écrire tels quels.

Bref, il s'agirait d'un nettoyage de la langue plutôt que d'une réforme profonde. Il vise sans doute surtout à nous mettre à l'heure orthographique internationale plutôt qu'à enclencher une révolution susceptible, d'ailleurs, d'échouer par suite des réactions passionnelles qu'elle entraînerait.

Depuis un siècle, de très nombreux pays ont ainsi procédé à une simplification de leur orthographe, portant principalement sur la suppression des lettres grecques et des consonnes parasites. L'Espagne, le Portugal, La Hollande, le Danemark, la Norvège, l'URSS ont allégé et assoupli leurs langues. Il s'agissait pour nous de n'être pas en retard. Ce n'est donc pas une reddittion inconditionnelle à l'orthographe phonétique.

Si les puristes soucieux de notre tradition littéraire peuvent donc rengainer leurs flèches,-on n'en a jusqu'ici relevé qu'un très petit pourcentage résolument opposé à toute réforme -il est permis de se poser que ques questions.

**1. La première est celle-ci :** d'ici la mise en application de ces réformes, que M. Bes ais ne prévoit que pour l'an 2.000, celles-ci ne serontelles par devenues insuffisantes ? Puisque le texte de l'arrêté est déjà prêt dans les tiroirs du Ministre, n'est-il pas possible de le promulguer un peu plus tôt ? **Et ceci non pas dans le seul but d'économiser aux écoliers des heures précieuses qu'ils pourront mieux consacrer à l'anglais, à l'alle mend. au russe, à l'arithmétique ou à la géométrie, mais pour amortir le choc chaque année plus violent que le langage parlé assène à la langue écrite.**

En France comme ailleurs, la radio et la télévision enflent chaque jour le volume des mots parlés ( et entendus, sans doute ), et font diminuer celui des textes lus. Inutile de passer au crible de la correction, même pas la correction grammaticale, le langage parlé de 1965, assemblage de style pédant, de sabir « franglais » et de locutions familières plus ou moins fortement teintées d'argot Non seulement le Français moyen trouve de moins en moins de temps pour écrire, si le désir lui en venait, mais même pour lire. Il est peut être plus urgent qu'on ne le pense d'alléger pour les jeunes français une orthographe dont la complexité les rebute et les rejette vers la langue parlée.

**2. La deuxième quesiion est celle-ci:** l'orthograqhe phonétique mérite-t-elle vraiment d'être traitée comme une éventualité honteuse et dégénératrice? Une langue telle que l'italien, par exemple, qui est étroitement liée à l'orthographe phonétique, est bien loin d'être dénuée de nuances ou d'avoir renié son passé Par surcroît, elle est d'un apprentissage infiniment plus aisé que le français.

Sans aboutir à quelque monstruosité linguistique, à quelque « français basique », la commission Beslais ne trouverait-elle pas profit à se rapprocher davantage de l'orthographe phonétique ? C'est pourtant une vertu qui n'est pas indigne du génie de Voltaire, Zola, de Claude Bernard, de Pasteur, que celle de la simplicité.

Et l'efficacité ? S'en soucie-t-on ? Après tout, nons vivons encore sous les lois édictées par le français qui se soucia le moins de l'orthographe: Napoléon !

# ទំព័រវប្បធម៌

## យុវជន នឹង រង្គសាល

ទីវ អុល នឹង ព៉ា សូឃិន

មិត្ត ព៉ា សូឃិន នៃអនុវិទ្យាល័យព្រៃដើមថ្នឹង ក្នុងការឆ្លើយតបនឹងសំណួររបស់គណៈកម្មាធិការនាយកនៃ ស. ស. ខ. បាននិពន្ធឡើងវិញនូវសេចក្តីអន្តរាគមន៍របស់ខ្លួនក្នុងសមាជជាតិមុននេះ ដែលបានទទួលសេចក្តីប្រោសប្រណីជាខ្លាំងពីសម្តេចសហជីវិន ហើយបានទទួលសេចក្តីសាទរពីសំណាក់សមាជិកសមាជជាកិយោភាព ។

មិត្តយើងពល់គ្នាច្បាស់ជាបានដឹងអំពីសេចក្តីសំរេចចិត្តរបស់សមាជជាតិលើទី ២០ អំពីបញ្ហា « បិទរង្គសាល » រួចហើយ ហើយក៏ប្រហែលជាបានឮអន្តរាគមន៍ប្រកបដោយសារៈសំខាន់របស់មិត្ត ព៉ា សូឃិន ដែរ ។ សមាជជាតិលើកទី ២០ ក្រោមព្រះរាជា-ធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចឪ បានសំរេចជាឯកច្ឆន្ទថា នឹងបិទរង្គសាលនៅភ្នំពេញទាំងអស់ លើកលែងតែមួយពីរចេញសំរាប់ជនបរទេសនឹងទេសចរ ។ សេចក្តីសំរេចនេះបានធ្វើឲ្យពលរដ្ឋទូទៅ ជាពិសេសយុវជនយើងមានសេចក្តីពេញចិត្តនឹងសោមនស្សសាទរជាពន់ពេក ព្រោះយល់ថាការនេះបង្កើតនូវលក្ខណៈល្អមួយដល់ការអប់រំខ្លួនគេ ។

យុវជនជាបុប្ផានៃសេចក្ដីសង្ឃឹមរបស់ជាតិ នឹងជានិមិត្តរូបនៃថាមពលនឹងសេចក្ដីស្អាតស្អំរបស់ប្រជាជាតិ ពុំនោះសោតទេ គឺជាអនាគត ជាគ្រឹះនៃប្រជាជាតិនីមួយ ៗ តែម្ដង ។ ការពិតនេះ សង្គមវិទូណាក៏ទទួលស្គាល់ដែរ ។ ហេតុដូចនេះហើយបានជាក្នុងបញ្ហា « បិទវង្គសាល »នេះ មានពក្ខិនជាច្រើនបានឡើងថ្លែងយោបល់បំភ្លឺសមាជ ដោយលាតត្រដាងគ្រប់ ៗ គ្នានូវឥទ្ធិពលដ៏ចង្រៃនៃវង្គសាលទៅលើការរីកលូតលាស់របស់យុវជនយើង ។

វង្គសាល ក្រៅពីផ្ដល់នូវពន្ធជាខ្លះដល់ថវិកាជាតិ បានបោះនូវបញ្ហាច្រើនបែបច្រើនយ៉ាងណាស់ដែលមិនងាយនឹងដោះស្រាយបានឡើយ ។ ពន្ធជានេះ បើប្រៀបធៀបទៅនឹងផលអាក្រក់ជាច្រើន ដែលវង្គសាលបានបង្កើតឡើង – ចំពោះនយោបាយនឹងសេដ្ឋកិច្ចប្រទេសជាតិក៏ដូចជាចំពោះសង្គមកិច្ច មានការអប់រំយុវជនជាដើម – មានសារៈសំខាន់ស្ដួចស្ដើងណាស់ ។ ផ្ទុយទៅវិញ ការបំបិទវង្គសាលដោយទុកតែមួយពីរសំរាប់បរទេស នឹងដោះស្រាយបាននូវបញ្ហាជាច្រើន ដែលមិនងាយនឹងដោះស្រាយបានតាមវិធីផ្សេងៗទៀតនោះ ។ បញ្ហាសំខាន់ខ្លះក្នុងចំណោមបញ្ហាសំខាន់ទាំងឡាយ ដែលកើតឡើងអំពីវង្គសាលមាន :

**ខាងនយោបាយ នឹងសេដ្ឋកិច្ច** វង្គសាលជាកន្លែងងាយស្រួល ដែលពួកជនទ្ប្រសជាតិ ពួកអ្នកផ្សងព្រេងនឹងអ្នករត់គយនិយមប្រើ ដើម្បីនឹង « គិតការ » ដ៏កខ្វក់របស់ខ្លួន ៗ យើងនៅចាំបានថា ក្នុងរឿង ឡាបាត់ វង្គសាលបរទេសខ្លះក៏មានការទាក់ទងជាមួយដែរ ។

**ខាងសង្គមកិច្ច** ការសប្បាយចាយវាយខ្ជះខ្ជាយលុយកាក់អស់ច្រើន នឹងនាំឲ្យមនុស្សខិតខំស្វះស្វែងរកលុយមកទៀត ទោះជាតាមវិធីសុចរិតក្ដី ទុច្ចរិតក្ដី–តែជម្មតាច្រើនតែទុច្ចរិត– ជាកត្តាមួយសំខាន់បង្កើតការស៊ីសំណូក ។ រីឯការសេពគប់ប្រឡូកប្រឡំគ្នា

រវាងអ្នកសុខសប្បាយនឹងអ្នកមានរោគ នឹងបណ្ដាលឲ្យរោគនេះតែធ្ងន់ទៅៗ ជាហេតុនាំឲ្យសុខភាពរបស់មហាជនជួបប្រទះនឹងឧបសគ្គ ឬនឹងគ្រោះថ្នាក់ជាអចិន្ត្រៃយ៍ ។

យើងពុំអាចនឹងអធិប្បាយអំពីផលវិបាកនៃរង្គសាលឲ្យបានពេញលេញ តែក្នុងក្របខណ្ឌនៃអត្ថបទចង្អៀតចង្អល់ប៉ុណ្ណោះទេ ។ ដូចនេះ យើងសូមលើកយកតែការទាក់ទងនឹងវប្បធម៌ ហើយនឹងការអប់រំយុវជនមកអធិប្បាយក្នុងទីនេះ ។

○

រង្គសាលបានជះឥទ្ធិពលអាក្រក់ច្រើនបែបច្រើនយ៉ាងណាស់មកលើយុវជនយើង ។ ដែលថាយុវជននេះ មិនមែនយុវជន យុវនារីទាំងអស់គ្នាទេ ប៉ុន្តែក៏ជាយុវជន យុវនារីមួយភាគធំដែរ ។ ដូចនេះ បញ្ហាដែលនាំឲ្យបារម្ភ – កាលពីមុនសំរេចបិទរង្គសាល – ម្យ៉ាងគឺបញ្ហាដែលយុវជនមួយចំនួនទទួលឥទ្ធិពលអាក្រក់ពីរង្គសាលមក ហើយម្យ៉ាងទៀតគឺបញ្ហាដែលយុវជនប្រភេទនេះផ្សាយឬចម្លងឥទ្ធិពលនោះដល់យុវជនឯទៀតៗ ។

ផ្លូវត្រឹមត្រូវសំរាប់យុវជនបណ្ដុះបណ្ដាលរាងកាយខ្លួន សុខភាពខ្លួន គឺជាផ្លូវដែលកីឡាករយើងបានដើររួចមកហើយ ហើយដែលទើបតែនឹងបញ្ជាក់ជោគជ័យថ្មីៗនេះនៅក្រុង ក្វាឡាលុំពួរ ។ ចំណែកឯរង្គសាលវិញមានត្រឹមតែបំផ្លាញរាងកាយ នឹងបំផ្លាញសុខភាពយុវជនតែប៉ុណ្ណោះ ដោយធ្វើឲ្យយុវជនយើងភាគខ្លះដក់ចិត្តសប្បាយភ្លេចខ្លួននឹងបរិយាកាសស្រើបស្រាល នឹងតន្ត្រីស្រើបស្រាល នឹងស្រី នឹងរបាំរាំរែក ដក់ចិត្តសប្បាយភ្លេចខ្លួននឹងការស៊ីផឹក ហើយអត់ងងុយស៊ូតស៊ាំងយ៉ាងអាក្រក់ ។ ចំពោះអ្នកខ្លះដែលមានការទាក់ទងខាងផ្លូវសព្ចោតនានឹងផ្លូវកាយជាមួយនឹងគ្នាទៀត នោះការអន្តរាយសុខភាពកាន់តែធ្ងន់ធ្ងរណាស់ទៅទៀត ។ យើងប៉ាន់មើល ! យុវជនដែលកំពុងតែត្រូវរែក

លូតលាស់ទៅតាមបែបបទស្អាតស្អំ ដូចជាកូនក្មេងជាតិដែលត្រូវការអាកាសធាតុល្អ ត្រូវការដីជាតិល្អ និងការថែទាំដិតដល់ដើម្បីនឹងលូតលាស់នោះ ហើយស្រាប់តែទៅប៉ះនឹងសញ្ចេតនាវេរវាយ ទៅប៉ះនឹងចំណីអាហារដែលសឹងចាត់ទុកជាពិសពុលបាន (ស្រី-ស្រា) ទៅប៉ះនឹងភេគសាហារ ទៅប៉ះនឹងការរៀនហាត់ឥតប្រយោជន៍ (បើជាការរៀនហាត់បង្កើតផលនោះមានអី !) ខុសវិទ្យាសាស្ត្រ (រាំរែកលោត រមួលនាំឲ្យខូចរាងកាយ ខូចឫកពាមារយាទ) តើការរីកលូតលាស់ខាងផ្លូវកាយនិងខាងផ្លូវចិត្តនេះ នឹងបត់បែនទៅតាមផ្លូវណាទៅ ? — រឿងនេះប្រាកដជាមិនមែនបត់ទៅតាមផ្លូវសុភមង្គលរបស់គ្រួសារ និងផ្លូវត្រូវការរបស់ជាតិទេ ! ដូចនេះ ហើយបុប្ផាដែលពោរពេញទៅដោយសំរស់ស្រស់ញញឹម ហើយផ្អែមល្ហែមទៅដោយទឹកដមដ៏ជោគជាំ ជាទីសង្ឃឹមនៃមាតាបិតានិងមាតុភូមិនេះ ក៏ប្រែក្លាយយ៉ាងឆាប់រហ័សមកនៅត្រឹមតែជាត្របកផ្កាដ៏ស្វិតស្វាំងទ្រុឌទ្រោមប្រុងតែនឹងជ្រុះមកលើគំនរសំរាម បង្កើតជាបញ្ហានាំឲ្យតែគេឯងរវល់ដោយសារទៅវិញ ។ នេះបានចំជាអាណោចអាធ័មមែន ! ក្រសួងមានសមត្ថកិច្ចត្រូវតែរវល់នឹងអ្នកជម្ងឺដូចនេះហើយ ប៉ុន្តែប្រសិនបើគ្មានអ្នកជម្ងឺប្រភេទ « ពិសេស » នេះទេ នោះក្រសួងសុខាភិបាលអាចនឹងទៅរវល់នឹងអ្នកជម្ងឺប្រភេទសមរម្យផ្សេង ៗ ដូចជាកម្មករ កសិករយើងដែលមានជម្ងឺព្រោះតែខិតខំ « កកាយធរណី » យកភោគផលមកចិញ្ចឹមជាតិ ឬយុវជនល្អដែលឈឺព្រោះខិតខំធ្វើការបង្កើតផល ឬខិតខំរៀនសូត្រទៅវិញ ។

តែកាលណាកម្លាំងកាយទ្រុឌទ្រោមហើយ ហើយជីវភាពបិតនៅក្នុងបរិយាកាសបែបនេះហើយ នោះប្រាជ្ញាស្មារតីក៏រាទៅឯងទេ ។ ស្តាប់សេចក្តីពន្យល់ដែលលោកគ្រូខំប្រឹងរៀបចំមកឯណានឹងចូល ស្តាប់សេចក្តីទូន្មានរបស់គ្រូ របស់មិត្តភក្តិ របស់សាលានិងរបស់មាតាបិតាឯណានឹងបាន ពិចារណាឬទន្ទេញមេរៀនឯណានឹងចាំ ប្រឡងត្រីមាសខាងកីឡាឯណានឹងកើតទៀត . . . រាស្រេចទៅហើយ ! លុះណាមួយតែយុវជន យុវ

នារីនោះដកខ្លួនចេញផុតពីបរិយាកាសនោះតែម្តង ទើបដោះស្រាយរួច ! ប៉ុន្តែនេះក៏ជាបញ្ហាតទៅទៀត. . . ដែរ ។

កម្លាំងកាយទ្រុឌទ្រោមនាំឲ្យប្រាជ្ញាទុនថយ ហើយក៏នាំឲ្យស្មារតីចុះទន់ទាបទៅតាមនោះដែរ ជាពិសេសគឺនាំឲ្យយុវជនប្រភេទនេះលែងស្គាល់ភារៈកិច្ចរបស់ខ្លួនជាយុវជនដែលមាតាបិតា និងប្រទេសជាតិរង់ចាំពីខ្លួនទៀតហើយ ។ យុវជនប្រភេទនេះស្តាប់សេចក្តីអំពាវនាវរបស់ប្រទេសជាតិមិនឮទេ ។ ទឹកមិនឃើញទេរឿងលំអវប្បធម៌ជាតិ រឿងការពារអាព្យាក្រឹតភាព រឿងស្នេហាពលកម្ម រឿងស្ថាបនាសេចក្តីចំរើនអ្វីៗ នោះ ។

ការបិទវគ្គសាលនេះ ពុំមែនគ្រាន់តែដោះស្រាយនូវបញ្ហា « យុវជនពាល » និងការខូចអនាគតរបស់យុវជន យុវនារីតែប៉ុណ្ណោះទេ ! ការបំបិទវគ្គសាលជួយយ៉ាងច្រើនដល់នយោបាយអព្យាក្រឹតភាពរបស់ជាតិដល់នយោបាយ " ជួយខ្លួន ដោយខ្លួនឯង » របស់ជាតិ ហើយផ្តល់នូវវិភាគទានមួយដ៏សំខាន់ដល់វប្បធម៌ជាតិ និងដល់បរិសុទ្ធភាពនៃយុវជន និងយុវនារីយើងទៀតផង ។

បណ្ណាគារ ម៉ិតនាង
លេខ 176 វិថីខេមរភូមិន្ទ ភ្នំពេញ
មានសេចក្តីរីករាយនឹងចុះថ្លៃ 10 % ចំពោះ សៀវភៅណាដែលផ្សាយចេញពីបណ្ណាគាររបស់ខ្ញុំ ។
សូមបង្ហាញបណ្ណសមាជិក !

# ស្នាដៃអាក្រក់

ពេលថ្មីៗនេះ យើងឃើញមានផ្សាយលក់តាមបណ្ណាគារ នូវសៀវភៅបែប :

" ប្ដីអញទេវើយ " " កម្លោះត្បាញអាយ មេម៉ាយយំយប់ " " ក្រមុំភ្ញា - ក កម្លោះស្វាឈាម "
" ស្នេហ៍អពមង្គល " " កុំហែកខោគាត់ " -ល- ។

ស្នាដៃដ៏អស្ចារ្យបែបខាងលើនេះ អធិប្បាយយ៉ាងផ្ដេសផ្ដាសតែពីស្នេហាដ៏កខ្វក់ ដោយប្រើពាក្យបំអាសបំអូងបំផុត ។

យើងមានសេចក្ដីសោកស្ដាយជាពន់ពេក ចំពោះសមត្ថភាព និងការព្យាយាមរបស់អ្នកនិពន្ធយើងក្នុងការបង្កើតស្នាដៃខាងលើ ដែលគ្មានប្រយោជន៍អ្វីក្រៅពីសាបព្រោះនូវការរើករាយ ផ្សាយនូវអំពើពាលដល់ពលរដ្ឋនិងយុវជន ដែលជាតិយើងកំពុងតែត្រូវការពឹងពាក់កម្លាំង ដើម្បីស្ថាបនាស្រុកទេស និងការពារទឹកដី ជាពិសេសក្នុងពេលបច្ចុប្បន្ននេះ ដែលបក្រពត្តិអាមេរិកាំងនិងបរិវារ កំពុងតែគំរាមកំហែង ។

ហេតុនេះហើយ បានជាយើងយល់ស្រប និងឧបត្ថម្ភយ៉ាងពេញទំហឹងនូវសារាចរ នៃសមាគមអ្នកនិពន្ធខ្មែរ ដែលអំពាវនាវចំពោះសមាជិករបស់ខ្លួន ឲ្យប្រុងប្រយ័ត្នជៀសវាង :

ទី ១– នូវការនិពន្ធរឿងដែលមិនគប្បី ហើយប៉ះពាល់ដល់តម្លៃអារ្យធម៌ជាតិយើង

ទី ២– នូវការប្រើពាក្យពេចន៍បំអាសបំអូង មិនពីរោះពិសា ចំពោះសីលធម៌ជាតិជាដើម

ទី ៣– នូវការនិពន្ធរឿងឥតខ្លឹមសារ គ្មានឧត្តមគតិ ហើយដែលនាំមានផលវិបាកអាក្រក់ ចំពោះយុវជនក្នុងបច្ចុប្បន្ន ឬទៅអនាគតកាល ។



# វត្ថុបទ & ឯកសារ

## ធម្មជាតិវិទ្យា

### អំពី អុតធំ

ដោយ ម៉ម ណៃ

វិទ្យាល័យ កំពង់ធំ

តាំងតែអំពីបុរាណកាលមក អុតធំបានកើតនៅបូព៌ាប្រទេស ។ ប្រទេសនោះគឺប្រទេសចិន ប្រទេសប៉ែរ្ស (Perse) នឹងប្រទេសកូកាស៊្សី (Caucassie) ។ បន្ទាប់មក អុតធំបានពលដាលដល់ប្រទេសអឺរ៉ុប (Europe) ។ រានេះជាជម្ងឺកើតឡើងដោយសាររមេរោគ ហើយថែមទាំងជាជម្ងឺឆ្លងទៀតផង ។ ក្នុងរយៈដ៏ខ្លីនេះ គឺពីសតវត្សរ៍ទី ១៧ ទៅទី ១៩ អុតធំបានផ្ដាច់ជីវិតមនុស្សលោកអស់រាប់ពាននាក់ ។ តែក្នុងបច្ចុប្បន្ននេះ យើងមានសំណាងល្អណាស់ ពីព្រោះរោគដ៏សាហាវនេះ បានវិនាសពីផែនដីនេះ ស្ទើរតែគ្រប់កន្លែង គ្រប់ទិសទី ។ ទាំងនេះក៏មកតែអំពីវិទ្យាវិទូ នឹងវេជ្ជវិទូដែលបានរកឃើញថ្នាំចាក់បង្ការអុតធំនោះដែរ ។

## ក– រោគលក្ខណៈ (symptômes)

រោគលក្ខណៈ គឺនិមិត្តហេតុ ឬសញ្ញានៃជម្ងឺ ។

អុតធំចាប់ផ្ដើមឡើងតាមលំដាប់យ៉ាងនេះ ៖

១– រយៈបង្ករោគ (période d'incubation)-

ពេលមានកំណត់ត្រឹមតែ ១២ ថ្ងៃ ៗ ក្នុងពេលនេះហើយ មេរោគអុតបានចូលមកសំងំ តាំងលំនៅ នៅក្នុងខ្លួនមនុស្សជាធម្មតា ៗ មនុស្សជានេះ គឺមនុស្សមិនឈឺ ហើយត្រូវនឹងពាក្យ «អោមសាំង» (homme sain) ៗ មនុស្សនេះមិនមានឈឺទេ គេនៅតែជាមនុស្សជាម្នាក់ ៗ

២_ រយៈកើតរោគ (période d'invasion)

ពេលនេះមានកំណត់ពី២ទៅ៣ថ្ងៃ ៗ នេះជាគ្រាដំបូងដែលមនុស្សជាអម្បាញ់មិញ ចាប់ផ្ដើមឈឺ ៗ តែក្នុងពេលនេះគេពុំអាចដឹងថា គេកើតជម្ងឺអ្វីឡើយ ៗ គេរងាញ័រទាំងប្រាណ ៗ គ្រុនក្ដៅកើតឡើងភ្លាម ៗ ខ្លួនគេក្ដៅដល់ទៅ ៤០ ឬ ៤១° C (°C= ដឺគ្រេសេ តាមមតិខ្ញុំ ដឺគ្រេស្រួលហៅជាង អង្សា) ៗ ជាមួយគ្នានោះ គេឈឺក្បាល ឈឺចង្កេះ ចង្អោរ រួចក្អួត ហើយគេដេករវើរវាយ ៗ

៣_ រយៈអាសន្ន (période d'état)

រយៈនេះមានកំណត់ពី ១១ ទៅ ១២ ថ្ងៃ ៗ អុតធំបានបង្ហាញរូបរាងកាន់តែច្បាស់ហើយ ៗ គ្រុនក៏ស្បើយ អ្នកជម្ងឺក៏អន់ថយ ៗ កន្ទួលក្រហមប៉ុន ៗ ចុងបង្កើះចេញនៅមុខ មាត់ ស្បែកនឹងអវយវៈ ៗ រាល់កន្ទួលក្រហមពកឡើង ៗ ពេលនេះកន្ទួលក្រហមមានជា «ពង» ទៅវិញ ៗ ក្នុងពងនីមួយ ៗ យើងឃើញមានទឹកថ្លាឈ្វេង ៗ ទឹកនេះគឺទឹកថ្លែង ៗ តមកទៀត ទឹកថ្លែងដែលពីដើមថ្លា ត្រឡប់ទៅជាល្អក់វិញ ៗ ទឹកថ្លែងល្អក់គឺខ្ទុះ ៗ ក្នុងពេលមានខ្ទុះនោះ គ្រុនរឹតឡើងវិញ ភាពអាសន្នកើតឡើងដែរ ៗ រីឯអ្នកកើតអុតធំ នឹងដឹងថារស់ឬស្លាប់ក្នុង ៩ ឬ ១០ ថ្ងៃទៀត ៗ

ប្រសិនបើគេស្លាប់ ពងទាំងអស់នឹងបែកតែម្ដងព្រមគ្នា ៗ ខណៈនោះស្បែកគេ

រំហែកគ្មានសល់កន្លែងណាឡើយ ។ ខ្លួនមានសុទ្ធតែដំបៅ ។ ឈាមគេហូរចេញឥតស្រាកស្រាន្ត ។ សួតគេទាំងពីរព្រមទាំងបេះដូងគេដើរកាន់តែអាក់អួលឡើងៗ ។ រំពេចនោះសួតនឹងបេះដូងមានវិបត្តិកម្ម ។ មច្ចុរាជបានស្ទុះចូលមកផ្តាច់ជីវិតជនអភ័ព្វដោយឥតមេត្តាបន្តិចសោះ ។

ផ្ទុយទៅវិញប្រសិនបើអ្នកជម្ងឺត្រូវមានជីវិតរស់នៅ អុតបែកមិនស្រុះគ្នាទេ ។ ៦ កំដៅក៏ចុះ ខ្ទុះក៏ខះក្រៀមបង្កើតបានជា « ក្រមរ » ។ ក្រមរ ទាំងនោះនឹងជ្រុះអស់នៅថ្ងៃទី ២០ ក្រោយថ្ងៃកំណើតវា ។ ក្រមរជ្រុះទៅ តែបានទុកសំឡាកនៅរហូតមួយជីវិត ។ ដូចនេះ យើងងាយចំណាំអ្នកកើតអុតធំណាស់ ពីព្រោះនៅលើមុខអ្នកនោះមានសុទ្ធតែសំឡាក ។ មុខបែបនេះហៅថា « មុខខ្ទិតស៊ី » ។

៤- ភាពជើបពីឈឺ (convalescence)

អុតធំហើរអស់ហើយ ។ គេមានកម្លាំងបន្តិចម្តងៗ ។ រីឯការអាស្រ័យបាយឆ្ងាញ់ ក៏មានឡើងវិញដែរ ។

## ខ- មេរោគ (agent pathogéne)

មេរោគជាភ្នាក់ងារជម្ងឺ ពោលគឺជាបុព្វហេតុរបស់អុតធំ ។ ដូចនេះ អុតធំកើតឡើងដោយសារមេរោគម្យ៉ាង ។ មេរោគនោះគឺ " វីរុសអុតធំ " ( virus variolique) ។ សត្វដ៏តូចនេះអាចមើលឃើញតែនឹងអតិសុខុមទស្សន៍អេឡិចត្រូនិក( microscope électronique) ។ សត្វដ៏មហាតូចទាំងនេះមានរាងមូល ។ វាមានវិជ្ជមាត្រ ( diamètre)០,២ មីក្រុង (១ មីក្រុង= $\frac{១}{១.០០០}$ មីលីម៉ែត្រ ឬ ១០$^{-៣}$ មម ) ។ វាអាចរក្សាទុកអានុភាពចង្រៃរបស់វា ( son pouvoir pathogène) បាន ២ ឬ ៣ សប្តាហ៖ ( អាទិត្យ ) កាលណាវានៅក្នុងខ្ទុះ ឬ ក្នុងក្រមរស្ងួតក្រៀម ។

ដូចនេះ ប្រសិនបើយើងយកឈាម ខ្ទុះ ឬក្រមរអ្នកកើតអុតធំ ទៅចាក់ ឬប្រឡាក់អ្នកជា (មនុស្សជា) ម្នាក់ ហើយដែលជាមនុស្សជម្ងឺ (មនុស្សឆាប់ឈឺ = homme réceptif) អ្នកនោះនឹងកើតអុតធំជាមិនខាន ក្នុងពេលឆាប់ ៗ ។

## គ– ការឆ្លង (contagion)–

អុតធំជារោគឆ្លងបំផុត ។ វិសាណូ-មេរោគ-អុតធំ អាចចូលទៅក្នុងខ្លួនយើងបានតាមច្រមុះជាដើម ។ ដូចនេះ ការឆ្លងមានពីរយ៉ាងគឺ :

– ការឆ្លងផ្ទាល់ (contagion directe)

– ការឆ្លងវាង (contagion indirecte)

### ១– ការឆ្លងផ្ទាល់

ការឆ្លងបែបនេះ គឺការឆ្លងពីម្នាក់ទៅម្នាក់ទៀតដោយបានប៉ះគ្នា ។ ឧទាហរណ៍ ប្រសិនបើយើងទៅពាល់ទៅស្ទាប ទៅលើកទៅបីអ្នកកើតអុតធំ ក្នុងពេលកំពុងកើត ឈាមឬខ្ទុះអ្នកនោះ នឹងប្រឡាក់ខ្លួនយើង ស្បែកយើង ។ យើងបានឃើញថាវិសាណូអុតធំ ស្ថិតនៅក្នុងខ្ទុះឈាមនឹងក្រមរ ។ ដូចនេះ មេរោគអុតធំ នឹងចូលទៅក្នុងខ្លួនយើង ហើយយើងនឹងកើតអុតធំនោះដែរ ។

### ២– ការឆ្លងវាង

ការឆ្លងវាងជាការឆ្លងតាមរបស់អ្វីមួយ ពោលគឺការឆ្លងពីម្នាក់ទៅម្នាក់ ដោយវត្ថុប្រើប្រាស់នៃអ្នកជម្ងឺកើតអុតធំ ។ ការនេះមានឧបមាដូចនេះ : ប្រសិនបើយើងទៅប៉ះពាល់សៀវភៅ ខោអាវ ខ្នើយ កន្ទេល នឹងសំបុត្រអ្នកកើតអុតធំ ដែលមានប្រឡាក់ខ្ទុះ យើងនឹងកើតមួយរំពេច ។ ចំណែកឯសំបុត្រប្រឡាក់ខ្ទុះ អម្បាញ់មិញនេះ ជាសារមួយដ៏អប្រិយ ពីព្រោះវានឹងសាបព្រោះ ពោលគឺបង្កើតអុតធំ នៅស្រុកណាដែលវាបានឈប់សំណាក់ ។ នេះហើយលទ្ធផលនៃការឆ្លងវាង ។

## ឃ- វិធីបង្ការរោគ (prophylaxie)

វិធីបង្ការរោគជាក្បួនមួយដែលយើងត្រូវតែប្រតិបត្តិតាមដើម្បីការពាររោគឆ្លង ។ ក្បួននេះមានពីរយ៉ាងគឺ ៖

– ជៀសវាងការឆ្លង

– ធ្វើឲ្យមានភាពស៊ាំនឹងរោគ ឬ បដិលាភភាពស៊ាំនឹងរោគ acquisition de l'immunité) ។

### ១– ជៀសវាងការឆ្លង

យើងបានដឹងហើយថាការឆ្លងមាន ២ បែប ៖ ការឆ្លងផ្ទាល់នឹងការឆ្លងវាង ។ ដោយហេតុនេះ យើងត្រូវ :

– ដាក់អ្នកកើតអុតធំក្នុងបន្ទប់មួយតែម្នាក់ឯងនៅផ្ទះ ឬ មន្ទីរពេទ្យចំនួន ៤០ ថ្ងៃ ។ ក្នុងរយៈ ៤០ ថ្ងៃនោះ មានតែគ្រូពេទ្យព្យាបាលនឹងអ្នកថែជម្ងឺទេ ដែលចេញចូលក្នុងបន្ទប់នោះបាន ។ មុននឹងចេញពីបន្ទប់អ្នកទាំងពីរត្រូវលាងដៃនឹងសាប៊ូ ហើយដោះអាវពេទ្យ (blouse) ទុកក្នុងបន្ទប់នោះ ។ ក្នុង ៤០ ថ្ងៃនេះទៀត អ្នកកើតអុតធំ គ្មានអំណាចនឹងសរសេរសំបុត្រផ្ញើឲ្យគេឡើយ ហើយមិនអាចឲ្យគេចូលមកសួរសុខទុក្ខទេ ។

– ស្ងោរបំបាត់មេរោគ (désinfecter) សំលៀកបំពាក់របស់ប្រើប្រាស់ នឹងបន្ទប់អ្នកកើតអុតធំ ។

### ២– រកឲ្យបានភាពស៊ាំនឹងរោគ:

គឺត្រូវតែបណ្ដុះអុតធំ ។ ការបណ្ដុះអុតមានដូចនេះ ៖

- ការបណ្ដុះអុតបុរាណ (la variolisation)

ការបណ្ដុះអុតបែបបុរាណមានតាំងពីយូរយាមក ។ សម្បត្តិនេះបានចាប់កំណើតក្នុងក្រុមអ្នកស្រុខ្ទ ៗ ។ ចិនម្នាក់បានមានគំនិតបណ្ដុះអុត ។ ដូចនេះ នៅលើដីនឹង

ក្រោមមេឃ មានតែចិនទេដែលមានវិទ្យា
គំនិតមុនគេ ។ ក្រោយមក ទើបការបណ្ដុះ
អុតបែបបុរាណ បានកើតនៅបូព៌ាស្រុក
នឹងប្រទេសតួកគាស៊ី ។ គេសង្កេតឃើញ
ថា អ្នកកើតអុតម្ដងហើយ អ្នកនោះមិន
កើតអុតទៀយ ហើយអុតធំស៊ីមុខមនុស្ស
ចាស់ជាងមុខកូនក្មេង ។ ដោយហេតុទាំង
នេះ ការបណ្ដុះអុតប្រសូតចេញក្លាម ។ ជន
មិនស្គាល់ឈ្មោះម្នាក់ បានយកបន្ទាទៅដោះ
« ពង » អុតអ្នកកើតស្រាលម្នាក់ ( un varioleux bénin ) ។ គេយកបន្ទាដ៏មានខ្ទុះ
នោះទៅចូតស្បែកក្មេងជាម្នាក់ទៀត ។ កុមារ
នោះគ្រាន់តែឈឺក្បាល ក្ដៅខ្លួនបន្តិចបន្តួច
ចេញអុតធំយ៉ាងស្រាលមួយ ហើយជាទៅ ។
ក្មេងនោះមានភាពស៊ាំនឹងរោគ គឺមានអនុ-
ភាពអ្វីម្យ៉ាងសំរាប់ប្រឆាំងនឹងមេរោគអុត ។

ការបណ្ដុះបែបបុរាណបានជួយមនុស្ស
ឲ្យគង់ជីវិតជាច្រើននាក់ ។ ទុកជាមាន
លទ្ធផលល្អប្រសើរខ្លះក៏ដោយ ក៏នៅតែ
មានលទ្ធផលអាក្រក់ដែរ ។ ផលអាក្រក់
នោះមានរហូតដល់បាត់បង់ជីវិត ។

យើងអាចអនុវត្ត នូវការបណ្ដុះអុត
នេះយ៉ាងដូចនេះ ៖

— យើងឲ្យអ្នកជា (មនុស្សមិនឈឺ)
ទៅដេកជាមួយនឹងអ្នកកើតអុតធំស្រាល ។

— ឬក៏យើងយកក្រមរអ្នកកើតអុត
ស្រាលមកផ្លុំបញ្ចូលក្នុងច្រមុះមនុស្សជា ។

— ឬក៏យើងឲ្យមនុស្ស មិនដែលកើត
អុតប្រើប្រាស់សំលៀកបំពាក់អ្នកកើតអុតធំ
ស្រាល ។

បុរាណវិធីនេះបានផ្សាយពីបូព៌ាប្រទេស
ទៅដល់កុងស្តង់ទីណូប (Constantinople) ។
នៅប្រទេសនេះ នាក្រុងតិស្សាលី (Thessalie) អ្នកក្រុងម្នាក់បានបណ្ដុះអុតបែបបុរាណ
ជាលើកដំបូងក្នុងឆ្នាំ ១៦៧៣ ។ ក្រោយ
មកទើបការបណ្ដុះបែបនេះ ផ្ទុតផ្ទោបដល់
ប្រទេសអឺរុប ( Europe ) ។ ដំបូងបង្អស់
ស្ត្រីអង់គ្លេសម្នាក់ឈ្មោះអ្នកស្រី ឡាឌី ម៉ុង
តាក ( Lady Montaque ) បានទៅនៅក្រុង
តិស្សាលី ។ អ្នកស្រីភរិយាទូតនេះ បានស៊ើប
នឹងការបណ្ដុះអុតនៅក្រុងតិស្សាលីណាស់ ។
នៅឆ្នាំ១៧២០ អ្នកស្រីបានប្រើរបៀបបណ្ដុះ

អុតខាងលើនេះនៅស្រុកខ្លួន ។ នា.គ.ស. ១៧២២ រាជវង្សានុវង្សនៃក្រុងឡុងដ៍ បាន យល់ព្រមបណ្ដុះអុតបែបបុរាណនេះដែរ ។ ការបណ្ដុះអុតនេះ បានបោះជំហានដល់ ប្រទេសបារាំង ។ ស្ដេចប្រទេសនេះ បណ្ដុះ តាមស្ដេចអង់គ្លេសក្នុងឆ្នាំ ១៧៤៤ ទៅ ។

● ការបណ្ដុះអុតបែបថ្មី ( vaccination antivariolique )

មុននេះជាការបណ្ដុះអុតបែបស្យង្យ ។ ការបណ្ដុះអុតនេះ ជាស្នាដៃលោក យ៉ែនើរ (Jenner) ។ លោកបានរកឃើញការបណ្ដុះបែបស្យង្យ នៅចុងសតវត្សទី ១៨ ។

ជិន ណែរ កើតនៅឆ្នាំ ១៧៤៩ ។ លោកស្លាប់ទៅវិញនៅ ឆ្នាំ ១៩២៣ ។ លោកជាគ្រូពេទ្យ (médecin) អង់គ្លេស ម្នាក់ ។ កាលពីអាយុ ២១ ឆ្នាំ លោកជាសិស្ស លោក យ៉ន ហាន់ទើរ ( John-Hunter ) ។ លោកបានទំរៀនតិចនិច នៃការបណ្ដុះអុត បុរាណណាស់ ព្រមទាំងយកទៅអនុវត្ត ផង ។ ក្នុងការអនុវត្តនោះ លោកបានជួប ប្រទះនឹងបានស្គាល់ បានយល់នូវគ្រោះថ្នាក់ នឹងផលនៃការបណ្ដុះអុតបែបបុរាណ ។

ដោយលោកជាមនុស្សស្វិតស្វាញ ក្នុងការងារ លោកបានសង្កេតឃើញកុមារ កុមារី ដែលជាគង្វាលគោ មិនសូវកើតអុត ធំទេ នៅពេលរោគនេះកើតពេញទាំងភូមិ ទាំងស្រុក ។ លោកនឹកឆ្ងល់ ។ លោក ទៅពិនិត្យមើលដៃជើងក្មេងទាំងនោះ ។ ដៃ នឹងជើងក្មេងទាំងនោះ មានសំឡាកដូចសំ- ឡាកអុតធំ ។ រីឯដោះមេគោក៏មានសំឡាក នេះដែរ ។ សំឡាកនៅនឹងដោះមេគោ ដោះជាស្នាមអុតគោ ។ អុតគោនេះមាន ឈ្មោះថា ខៅ ប៉ុក ( cow-pox ) ។ ដូច នេះ លោក យ៉ែនើរ សន្និដ្ឋានថា « អុត មេគោ បានផ្ដល់អានុភាពម្យ៉ាង ពោលគឺ ភាពស៊ាំនឹងរោគ ( immunité ) ដល់កុមារ គង្វាល ។ អានុភាពនេះ បានការពារក្មេង មិនឲ្យកើតអុតធំ ។

ថ្ងៃ ១៤ ឧសភា ឆ្នាំ ១៧៩៦ បាន មកដល់ ។ ជិន ណែរ បានយកខ្ទុះអុត មេគោដោះ ទៅចាក់ឲ្យក្មេងជាម្នាក់ ( un

enfant sain ) ។ ក្មេងនេះបានកើតអុត-ស្រាល ។ ជម្ងឺនេះមិនធ្ងន់ទេ រួចក្មេងនោះជាទៅ ។

ដល់បាន ១ ខែ កន្លះជាង គឺថ្ងៃ ១ កក្កដា ឆ្នាំ ដដែល ដិន ណែរ បានយកខ្ទុះស្រស់នៃអុតធំទៅចាក់ឲ្យក្មេង ដែលយើងបានពោលអម្បាញ់មិញនេះ ។ ក្មេងនោះពុំមានកើតអុតធំឡើយ ។ ការបណ្ដុះអុតបែប យ៉ែនើរ បានកើតឡើងហើយ ។ ការបណ្ដុះអុតបែបស្រៀង-បែបថ្មី បានមកផ្លាស់ការបណ្ដុះបែបបុរាណ ។

ការពិសោធន៍បានសម្រេចនូវផលល្អ ៗ លោក យ៉ែនើរ ចាប់ធ្វើថ្នាំចាក់បង្ការអុតដូចនេះ : លោកយកមេគោក្រមុំ (ជំទង់ល្អជាង ) ដែលគ្មានរោគមកកោររោមត្រង់ឆ្អឹងជំនីរឲ្យរលីង ។ លោកឆូតស្បែកពានឹងប្រដាប់ឆូត ដែលមានរាងដូចស្លាបប៉ាកាដែ ( la plume ) ។ យ៉ែនើរ យកខ្ទុះអុតមេគោដោះទៅលាបត្រង់កន្លែងឆូត ៗ នៅកន្លែងនោះ មានឡើងកន្ទួលក្រហមជាំ រួចពងមានទឹកថ្លៃ ។ ទឹកថ្លៃប្រែទៅជាខ្ទុះ ហើយពងនោះបែក រួចក្រមរក៏មានកើតឡើង ៗ ក្រោយក្រមរមានអាយុ ដប់ថ្ងៃហើយ លោកបេះយកវា ។

លោកយកក្រមរទៅកិននឹងគ្លីសេរីន ( glycérine ) ឲ្យល្អិត ហើយត្រូវយកទឹកម្យ៉ាងទៀត គឺថ្នាំចាក់បង្ការអុតធំ (le vaccin antivariolique ) ។ គេប្រកថ្នាំនេះទុកក្នុងអំពូល ឬ កូនដប ហើយបិទមាត់ជិតរួចដាក់ទៅក្នុងទូត្រជាក់ ដែលមានសីតុណ្ហភាព ១០ °C ។

គេបានប្រើវិធីច្រើន ដើម្បីដោះបណ្ដុះអុត ។ កាលពីមុនគេដោះអុតនឹងប្រដាប់ម្យ៉ាង ដូចស្លាបប៉ាកាដែ ៗ គេឆូតដើមដៃ បីកន្លែង ៗ នៅកន្លែងនីមួយ ៗ មានឆូតបី ៗ រួចគេផ្តិតថ្នាំបង្ការអុត ។ បី - បួន ថ្ងៃក្រោយមក កន្លែងដោះឡើងក្រហមហើយមានពង-ពងមានទឹកថ្លៃ — ទឹកថ្លៃប្រែទៅជាខ្ទុះ រួចបែកទឹកកកើតជាក្រមរ — ក្រមរជ្រុះទុកសំ-ឡាក ដូចកើតអុតមែនទែនអ៊ីចឹង ។ ក្រោយពីដោះកើតដូចនេះ អ្នកដែលដោះកើតមានអានុភាពម្យ៉ាង — ភាពស៊ាំនឹងអុត ។ អានុ-

ភាពនេះ អាចការពារអុតធំបានចំនួនដប់ឆ្នាំ ឆ្ងាយ ឬមួយជីវិតក៏មាន ។

ផ្ទុយទៅវិញប្រសិនបើដោះហើយមិនកើតដល់ ៧ ថ្ងៃក្រោយមកទៀត គេត្រូវបណ្ដុះអុតម្ដងទៀត ។

ក្នុងបច្ចុប្បន្ននេះ ជាពិសេសនៅប្រទេសកម្ពុជាយើង គេចូលចិត្តចាក់ទឹងម្ជុល ធ្វើប៉ុងស៊ីយ៉ុង (Ponction) ។ គេយកម្ជុលដែលជ្រលក់ក្នុងថ្នាំបង្ការអុត ទៅចាក់យ៉ាងពក់ៗ នៅដើមដៃ ឬនៅក្លៀ ។

ជាទីបំផុត ហើយពិសេសនឹងសំខាន់បំផុត គេត្រូវទៅបណ្ដុះអុតរាល់ៗ ឆ្នាំ ទុកជាដោះកើត ឬមិនកើត ពីព្រោះ «ការពារទុកស្រណុកជាងកែខៃ» ។

## ង– ការពាររោគ (Traitement)

– ឲ្យអ្នកកើតអុតធំដេកនៅស្ងៀម

– ឲ្យអ្នកកើតអុតធំលាបប្រេងគោម៉េណូឡេ (huile goménolée) នៅលើស្បែក ។ ប្រសិនបើនៅស្រុកស្រែ គេឲ្យអ្នកជម្ងឺដេកលើស្លឹកចេក ។

–ឲ្យបរិភោគទឹកដោះគោ នឹងទឹកក្រូចប្រចាប់ (ក្រូចពោធិសាត់) ។

សូមមិត្តអានឱយចប់

ហើយឱយយោបល់ផង !

# ប្រវត្តិវិទ្យា

## ហ្វាស៊ិសនិយម នឹងរបបផ្តាច់ការ
## នៅក្រោយចំបាំងសាកលលោកលើកទី ១

ដោយ ម៉ៃ លង់

ក្រោយពីចម្បាំងសកលលោកលើកទី ១ បណ្តាប្រទេសនៅទ្វីបអឺរ៉ុបជាច្រើន បានជួបនឹងវិបត្តិគ្រប់បែបយ៉ាង ដែលជាបច្ច័យនៃសង្គ្រាមខាងលើ ហើយដែលជាហេតុបង្កើតឲ្យមានរបបហ្វាស៊ិសនិយមនឹងរបបផ្តាច់ការនៅប្រទេសអ៊ីតាលី-ប្រទេសអាល្លឺម៉ាញជាដើម ។

### ប្រទេសអ៊ីតាលី ពីឆ្នាំ 1919 - 1939

ក្នុងចំណោមប្រទេស ដែលរួមយកជ័យជំនះ ក្នុងចម្បាំងសកលលោកលើកទី ១ មានតែប្រទេសអ៊ីតាលីមួយទេ ដែលបានទទួលការផ្លាស់ប្តូរប្រែប្រួល យ៉ាងទូលំទូលាយ ជ្រៅជាងប្រទេសណា ៗ ទាំងអស់ ។ យ៉ាងណាមិញ ក្រោយពីបានពើបប្រទះនូវការច្របូកច្របល់អស់រយៈពេលមួយយ៉ាងយូរ ប្រទេសអ៊ីតាលីបានប្រែពីរបបនយោបាយប្រជាធិបតេយ្យ-សេរីភាព ( សភានិយម ) ទៅជារបបហ្វាស៊ិសនិយម ។ ការវិវត្តន៍ទៅរកហ្វាស៊ិសនិយមនេះ គឺជាបច្ច័យនៃសង្គ្រាមផ្ទាល់តែម្តង ។

## ក- វិបត្តិសេដ្ឋកិច្ច :

ក្រោយពីចម្បាំង ប្រទេសអ៊ីតាលីបានធ្លាក់ខ្លួនចុះទៅជាក្រីក្រជុនជាប ។ ស្ថានភាពសេដ្ឋកិច្ច បានធ្លាក់ចុះមួយកំរិតយ៉ាងខ្លាំង ហើយមានសភាពរឹងរឹតតែធ្ងន់ធ្ងរឡើងៗ ។ ក្រៅពីការលំបាកទាំងឡាយដែលជាប្រពៃណីរបស់ប្រទេសអ៊ីតាលី ដូចជាមនុស្សច្រើន ការយឺតយ៉ាវក្នុងការលូតលាស់ខាងសេដ្ឋកិច្ច មានការលំបាកជាច្រើនមកគ្របសង្កត់ថែមទៀត ។

— ក្នុងពេលចម្បាំង ប្រទេសអ៊ីតាលីបានខ្ចីប្រាក់ពីប្រទេសដទៃដើម្បីរៀបចំទ័ពនិងពង្រីកឧស្សាហកម្មសឹករបស់ខ្លួន ដែលជាហេតុនាំឲ្យជំពាក់បំណុលជាច្រើន ព្រមជាមួយនោះ ប្រាក់អ៊ីតាលីត្រូវបញ្ចុះថ្លៃ ។

—ក្រោយពីចម្បាំង សហគ្រាសឧស្សាហកម្មទាំងឡាយត្រូវរលំ ដោយគ្មានអ្នកណាទិញ ឬក៏ដោយសង្គ្រាមបំផ្លិចបំផ្លាញ ។

## ខ- វិបត្តិខាងសង្គម :

វិបត្តិខាងសេដ្ឋកិច្ចខាងលើ បណ្តាលឲ្យមានវិបត្តិខាងសង្គមថែមទៀត ។ ស្ថានភាពសង្គមបានធ្លាក់ចុះមួយកំរិតគួរឲ្យភ័យបារម្ភ ។ កសិករ ត្រូវហិនហោចខូចប្រយោជន៍ ។ អ្នកគ្មានការធ្វើមានចំនួនរឹតតែច្រើនឡើង ។ ចាប់តាំងពីឆ្នាំ ១៩១៩ មកគេសង្កេតឃើញមានបាតុកម្ម ឃើញមានការបះបោរ ការឆក់ប្លន់រឹតតែច្រើនឡើងៗ ។

អសន្តិសុខ មានពេញលើផ្ទៃប្រទេស ។ ក្នុងឆ្នាំ ១៩២០ កម្មករពេងស្ទែកចំនួន ៦០០.០០០ នាក់ បានបះបោរដណ្តើមកាន់កាប់រោងចក្រខ្លួនឯង ។ ការបលាបលខាងកសិកម្ម មានកើតពាសពេញប្រទេសទាំងអស់ ហើយក្លាយទៅជាចម្បាំងក្នុងស្រុកទៀតផង ដូចជានៅ ស៊ីស៊ិល-នៅខាងដីទំនាបប៉ូវជាដើម . . . ។

## គ- វិបត្តិខាងនយោបាយ :

ឈមមុខនោះនឹងការលំបាកទាំងនោះ មេដឹកនាំពុំបានចាត់វិធានការអ្វី ដើម្បីស្រោចស្រង់ប្រទេស ពីអនាធិបតេយ្យឡើយ ហើយពុំព្រមសម្រេចឲ្យមានការកែទម្រង់អ្វីជាច្បាស់លាស់ដែរ ។ ផ្ទុយទៅវិញ គេប្រើនតែឈ្លោះប្រកែក ប្រកាន់បក្ស ប្រកាន់ពួក ពុំចេះចប់ពុំចេះហើយកង់សភា ។ រដ្ឋាភិបាលបាត់បង់អស់អំណាចរកធ្វើការអ្វីមិនកើត ។

មហាសេដ្ឋី ដោយព្រួយបារម្ភខ្លាចបាត់បង់ផលប្រយោជន៍របស់ខ្លួន បណ្តាលមកពីបាតុកម្ម - ពីចលាចល - ពីការបះបោរទាំងនោះ បានគាំទ្រយ៉ាងពេញទំហឹងដល់គណៈបក្សហ្វាស៊ីសនិយមរបស់ លោកមុស្សូលីនី ដើម្បីទប់ទល់នឹងអណ្តាតភ្លើងបដិវត្តន៍ ដែលកំពុងតែឆេះរាលដាលលើប្រទេសអ៊ីតាលីទាំងមូល ។ នៅខែតុលា ១៩២២ មុស្សូលីនី បានដណ្តើមយកអំណាច ក្រោយពីបានធ្វើរដ្ឋប្រហារ ហើយកងទ័ពរបស់លោក ដែលមានឯកសណ្ឋានជា « សមិខ្មៅ » បានហែជាក្បួនយាត្រាយ៉ាងខ្លាំងក្លា នៅទីក្រុងរ៉ូម នាថ្ងៃទី ៣០ តុលា ១៩២២ ។

# លោកមុស្សូលីនី និងរបបផ្តាច់ការ

## ជីវប្រវត្តិសង្ខេប :

មុស្សូលីនី ជាបុត្រាជាងដែក លក់កាហ្វេម្នាក់ដែលមានឈ្មោះហៅជាក់ថា « កន្ទេងជួបជុំនូវក្បាលក្តៅទាំងឡាយ » ។ ដើមដំបូងលោកធ្វើជាគ្រូបង្រៀន តែក្រោយមកលោកត្រូវគេបណ្តេញចោល ដោយគំនិតបដិវត្តន៍របស់លោក ហើយក៏បានរស់នៅដោយគ្រោះថ្នាក់ព្រួសឯប្រទេសស្វីស ។ លោកចាកចោលប្រទេសស្វីស ចូលមកកាន់មាតុប្រទេសវិញ លោកបានធ្វើជាចាងហ្វាងកាសែតមួយឈ្មោះ « អាវ៉ាន់ទី » ដែលជា

ការសែតមាននិន្នាការខាងសង្គមនិយម ។ ចម្បាំងលោក ឆ្នាំ ១៩១៤ បានធ្វើឲ្យមុស្សូលីនី ប្រែទៅជាបុគ្គលមួយផ្សេងទៀត ។ ក្រោយចម្បាំង ក្រោយពីបានឃើញយ៉ាងជាក់ច្បាស់នូវការបះបោរនៃពពួកកម្មករ និង កសិករ លោកក៏បានផ្តាច់ការទាក់ទងនឹងគណៈបក្សសង្គមនិយម ហើយលោកក៏ចាប់ផ្តើមបង្កបង្កើតនូវគណៈបក្សមួយថ្មី ហៅថា « គណៈបក្សហ្វាស៊ីស » ។ មុស្សូលីនី ជាអ្នកពេញចិត្តនឹងខ្លួនឯង មានសេចក្តីអំនួត ហើយមានវោហារគ្បោះគ្បាយ អាចធ្វើឲ្យគេទាំងអស់គ្នា មានការរំភើបញាប់ញ័រ ក្នុងពេលដែលលោកនិយាយម្តង ៗ ។ គេអាចចាត់លោកដូចជាមនុស្ស « គ្របីស៊ីក្នុងអូរ ហើយស្គាល់ការជាក់ស្តែងដ៏ពិតប្រាកដ ។

លុះមុស្សូលីនីបានប្រមូលអំណាចទាំងអស់មកកាន់កាប់ ក្រោយពីបានធ្វើរដ្ឋប្រហារប្រកបដោយជោគជ័យ លោកក៏ចាប់ស្ថាបនានូវរបបហ្វាស៊ីសមួយ ពេញលើផ្ទៃប្រទេសអ៊ីតាលី ។ ចាប់តាំងពីឆ្នាំ ១៩២៥ សេរីភាពទាំងប៉ុន្មាន ត្រូវបាត់បង់អស់ : កាសែត - ភាពយន្ត - វិទ្យុ ត្រូវច្បាប់ហ្វាស៊ិសថ្មីត្រួតត្រាពិនិត្យទាំងអស់ ។ ក្នុងឆ្នាំ ១៩២៦ ដំណាងរាស្ត្រដែលជាគណៈបក្សដំទាស់ទាំងប៉ុន្មាន ត្រូវបណ្តេញចោលទាំងអស់ ។ ក្រសួងរដ្ឋបាល- កងទ័ព- ក្រសួងសិក្សាធិការ ត្រូវបានបំពេញទុកនៅតែអ្នកណាដែលមានសមានចិត្ត អនុគ្រោះដល់ហ្វាស៊ីសនិយម ។ ឯបក្សដំទាស់ត្រូវវិនាសសាបសូន្យ ។ មុស្សូលីនី បំបិទសិទ្ធិសេរីភាព ចាប់ចង ឃុំឃាំង ឬក៏និរទេសនូវគ្រប់ជនទាំងឡាយណាដែលមានគំនិត មានយោបល់មិនស្របនឹងលោក ។ មុស្សូលីនី បានបង្កើតនូវប៉ូលិសនយោបាយមួយ ដែលរមែងដើរសាបព្រោះ នូវសេចក្តីភិតភ័យ សេចក្តីតក់ស្លុត ក្នុងបណ្តាប្រជារាស្ត្រសព្វគ្រប់ ។

ដូច្នេះគេអាចសន្និដ្ឋានបានថា អំណាចរដ្ឋទាំងអស់ បានប្រមូលមកក្នុងកណ្តាប់ដៃនៃជនម្នាក់ ដែលជានាយក ជាអ្នកដឹកនាំ ដែលបានប្រមូលមកវែកលើ ស្មារបស់ខ្លួន នូវគ្រប់អំណាចរដ្ឋទាំងអស់ ។

ក្នុងបញ្ហាក្រៅប្រទេស ប្រទេសអ៊ី-តាលី សម័យហ្វាស៊ីសនិយម បានប្រកាន់យកនូវនយោបាយវាតទី តាំងទឹកដី នឹងដណ្ដើមយកដីធ្លីរបស់ប្រទេសដទៃទៀត ។ ដើម្បីសម្រេចនូវគោលបំណងខាងលើ មុស្សូលីនីបានរៀបចំទ័ព ទាំងខាងជើងគោក ទាំងខាងជើងសមុទ្រ ។ ក្នុងឆ្នាំ ១៩២៤ មុស្សូលីនី បានដណ្ដើមយកទីក្រុងយូហ្គោស្លាវីមួយឈ្មោះ ហ្វីអ៊ូម នឹងបានភ្ជាប់ប្រទេស អាល់បានី មកក្នុងប្រ-ទេសរបស់ខ្លួន ក្នុងឆ្នាំ ១៩៣៩ ។

ក្នុងទ្វីបអាហ្វ្រិក អ៊ីតាលី បានវាយយកប្រទេសអេស្យូពី ក្នុងឆ្នាំ ១៩៣៥-៣៦ ហើយនៅមុនចម្បាំងសកលលោកលើកទី២ ប្រទេសអ៊ីតាលី ពុំបានលាក់បាំងនូវគំនិតរបស់ខ្លួនដែលចង់វាយលុកលុយយកប្រទេសក្រិច ឡើយ ។

ក្នុងឆ្នាំ ១៩៣៧ ប្រទេសអ៊ីតាលី ក្រោមរបបហ្វាស៊ីសនិយម របស់មុស្សូលីនី បានចងស្ពានមេត្រីជាមួយនឹងប្រទេស អា-ល្លឺម៉ង់ ដែលមានឈ្មោះថា បន្ទាត់រោម-ប៊ែរលាំង ។ ប្រទេសជប៉ុនបានចូលរួមក្នុងប័ក្សនេះដែរ — ជាហេតុបង្កើតឲ្យមានប័ក្សមួយ ឈ្មោះប័ក្ស រោម ប៊ែរឡាំង តូក្យូ ដែលបានប្រមូលចូលក្នុងសម្ព័ន្ធរបស់ខ្លួន នូវរដ្ឋប្រកាន់ហ្វាស៊ីសនិយម ៣ ហើយដែលបានផ្ដើមគំនិតវាយលុកយ៉ាងសំបើម ក្នុងចម្បាំងលោកលើកទី ២ ។

★

★ ★

# សង្គ្រាមលោកលើក ទី ២

● ប្រទេសចំនួន ៧២ ដែលមានរាស្ត្រ ៨០ % នៃរាស្ត្រក្នុងពិភពលោកទាំងមូល បានចូលធ្វើសង្គ្រាមលោកទី ២ ។ ក្នុងសង្គ្រាមនេះ មានមនុស្សចំនួន ១១០ លាននាក់ បានចូលប្រឡូក ។

● តាមលេខរបស់ អ.ស.ប ទាហានស្លាប់លើរណសិរ្ស មានចំនួន ៣២ លាននាក់ ។ ការទំលាក់គ្រាប់បែកបានផ្តាច់ជីវិតមនុស្សអស់ ២៥ លាននាក់ ដែល ២ ភាគ ៣ ជាស្ត្រី នឹងកូនក្មេង ។

● សង្គ្រាមបានកំទេចម៉ត់នូវគេហដ្ឋាន ចំនួន ៣០ លានខ្នង ។

● មនុស្សចំនួនជាង ១០ លាន បានត្រូវគៀរពីប្រទេសនានា ដោយពួកហ្វាស៊ីស ដើម្បីយកទៅបង្ខំឲ្យធ្វើការធ្ងន់ៗ នៅអាល្លឺម៉ាញ ។

● ពួកហ្វាស៊ីស បានលួចប្លន់រាស្ត្រក្នុងដែនដីដែលវាត្រួតត្រា ។ ចាប់ពីខែ ឧសភា ១៩៤០ មកដល់ ខែ តុលា ១៩៤៤ ពួកវានេះបានឆក់ប្លន់ ក្នុងប្រទេសដែលវាជិះជាន់ នូវសម្បត្តិទ្រព្យ មានតម្លៃជាង ១២៨ កោដិ ម៉ាក-លុយអាល្លឺម៉ង់ ( នេះដោយមិនបានរាប់ ការលួចប្លន់នៅតំបន់នៃប្រទេសសូវៀត ដែលវាត្រួតត្រានោះចូលផង ) ។

● ការបំផ្លាញនឹង វត្ថុឧបភោគមានចំនួន :

— ២០ កោដិដុល្លា នៅប្រទេសប៉ូឡូញ

— ៩ — នៅប្រទេសយូហ្គោស្លាវី

— ២៣ — នៅប្រទេសបារាំង

— ១០ — នៅប្រទេសអ៊ីតាលី

# ទំព័រអក្សរសិល្ប៍

## រឿងទុំទាវ

ដោយ ឃុប - រិត

សេចក្ដីបញ្ជាក់ : ក្នុងការសរសេរអត្ថបទខាងក្រោមនេះ ខ្ញុំពុំមានសេចក្ដីប្រាថ្នា នឹងទុកការពន្យល់អត្ថបទនេះជាគំរូអ្វីសោះឡើយ ។ ប៉ុន្តែ ដោយដឹងខ្លួនច្បាស់ថា នៅមានការខ្វះខាត ទើបខ្ញុំសំរេចចិត្តយកមតិនឹងវិធីពន្យល់អត្ថបទរឿងទុំទាវនេះមកចុះផ្សាយ ក្នុងគោលបំណងចង់បានដឹង បានស្គាល់មតិយោបល់នៃមិត្តសាស្ត្រាចារ្យភាសាខ្មែរដូចខ្ញុំយ៉ាងនេះទៅវិញទេ ។

ហេតុនេះ មតិ សេចក្ដីរិះគន់នានារបស់មិត្ត នឹងត្រូវបានទទួលដោយដៃទាំងពីរ ហើយដោយកតញ្ញុតាទៀតផង ។

### 1. អត្ថន័យ

#### ក. បច្ច័យន័យ

##### ១– អត្ថបទ

– *គឺជាអត្ថបទអក្សរសិល្ប៍ខ្មែរនិយម*

– *និពន្ធកាលពី ព.ស. ២៤៥៨ គ.ស. ១៩១៥*

##### ២– អ្នកនិពន្ធ

– *ភិក្ខុ សោម ចៅអធិការវត្តកំព្រៅ ខេត្តព្រៃវែង ៗ*

*(អ្នកខ្លះថាជាស្នាដៃរបស់សន្ធរម៉ុក ប៉ុន្តែគ្មានអ្វីជាភស្តុតាងធំដុំ ដូចល្មមគួរទុកជាបានការ)ៗ*

## ៣- សង្គមបរិយាកាស

ក- សេដ្ឋកិច្ច :

— ផលិតកម្ម : មានតែកសិកម្ម ហើយទន់ខ្សោយថែមទៀត ។

— ពាណិជ្ជកម្ម : ជំនួញភាគច្រើនធ្វើដោយដូរគ្នាទៅវិញទៅមក (គោករបស់ទុំ ដូរជាមួយស្រូវរបស់អ្នកស្រុកត្បូងឃ្មុំ) ។

— គមនាគមន៍ : គ្មានផ្លូវគមនាគមន៍ (ធ្វើដំណើរដោយជើង រទេះគោ ឬទូក) ។

ខ- នយោបាយ :

- របបស្តេចគ្រាញ់

គ- វប្បធម៌ :

— ការសិក្សាអប់រំ :

- វត្តអារាមជាទីសិក្សាអប់រំ

- រៀនអក្សរ មន្តអាគម សិល្បៈ នីតិវិជ្ជាជីវៈ សព្វបែបយ៉ាង ។

— សាសនា :

- ពុទ្ធសាសនា ដែលពុំទាន់បានរៀបចំឲ្យមានរបៀបនៅឡើយ ។

— ទំនៀមទម្លាប់ :

- គ្រុំប្ចូលម្ប

- នំមិនធំជាងនាឡិ ។

— ជំនឿ :

- សែនព្រេន តាយទស្សន៍... ។

## ខ. រូបន័យ - សាច់រឿង

### ១– តួអង្គ :

ព្រះកមា

| | |
|---|---|
| សង្គមមនុស្ស | ទុំ |
| លោកគ្រូចៅអធិការ | ទាវ |
| ម្ដាយទាវ | ពេជ្រ |
| អរជូន | នាងនោ |
| ម៉ឺនងួន | |

### ២– កាលអាកាស

– កើតនៅឋានមនុស្ស ស្រុកខ្មែរ (ត្បូងឃ្មុំ-លង្វែក)

– សតវត្សទី ១៦ ?

### ៣– ចលនា :

ក– ដំណើររឿង

ផ្នែកដំបូង រឿងទុំទាវនិយាយអំពីឧបសគ្គផ្សេង ៗ ដែលរាំងដំណើរស្នេហាដ៏ស្មោះត្រង់របស់ទុំ និង ទាវ ។

បន្ទាប់មក អ្នកនិពន្ធនិយាយអំពី អំពើឃោរឃៅរបស់អរជូន និងបក្សពួក ដែលបាន បំបែកបំបាក់ ទុំ ទាវ ហើយបំបាត់ជីវិតអ្នកទាំងពីរថែមទៀត ។

ទីបំផុត គឺការកាត់ទោសអរជូន និងបក្សពួកនៅត្បូងឃ្មុំ ។

ខ– ចលនានៃអត្ថន័យ

អត្ថបទនេះ ចែកជា ៣ ផ្នែក :

– ផ្នែកទី ១ : សេចក្ដីស្នេហានៃទុំ និងទាវ.

ផ្នែកទី ១ នេះ មានបី ខណៈ

– ខណៈ ទី ១ : ទុំលួចសឹក

– ខណៈ ទី ២ : ទុំ - ទាវ ស្រឡាញ់គ្នាមុនរៀបការ

– ខណៈ ទី ៣ : ទុំ ទូលការពិតចំពោះព្រះពជា

– ផ្នែក ទី ២ : មរណភាពនៃទុំនឹងទាវ

– ផ្នែក ទី ៣ : ការកាត់សេចក្ដីនៅត្បូងឃ្មុំ

## គ- នាមន័យ - ចិត្តរឿង

### ១– មូលន័យ

រឿងទាំងមូលបញ្ជាក់អំពីការកសាងសុភមង្គលមិនសម្រេចនៃយុវជនពីររូប គឺទុំ នឹងទាវ ដែលមានសេចក្ដីស្នេហាដ៏ស្មោះត្រង់ នឹងជ្រាលជ្រៅរវាងគ្នាទៅវិញទៅមក ។

### ២– បញ្ហាចោទ ( មូលបញ្ហា )

រឿងទុំទាវ ចិតនៅលើមូលបញ្ហាមួយដែលសួរថា តើហេតុអ្វី បានជាទុំ នឹង ទាវ ដែលមានសេចក្ដីស្នេហាទៅវិញទៅមកយ៉ាងជ្រាលជ្រៅនឹងយ៉ាងស្មោះត្រៃលែង បែរជាទៅឃើញសេចក្ដីស្នេហានេះវិនាសបាត់បង់ ហើយត្រូវរលត់ជីវិតទាំងពីរនាក់ថែមទៀតដូចនេះ ?

មូលបញ្ហានេះ អ្នកនិពន្ធបានយកមកបង្ហាញជាទំនាស់កុងផ្នែក នឹងខណៈផ្សេង ៗ ដូចតទៅនេះ :

# ការចោទបញ្ហា_

## ផ្នែកទី ១

— ខណៈ ទី ១ ( ទុំលួចសឹក ) :

គឺជាទំនាស់រវាងលោកគ្រូ តំណាងទំនៀមទំលាប់ - ជំនឿ ( សឹកត្រូវមានអនុញ្ញាតិពីគ្រូជាមុន - តាមហោរាសាស្ត្រ តែសឹកត្រូវស្លាប់ ) ហើយនឹងទុំ ដែលដឹងខ្លួនច្បាស់ថាពុំអាចទ្រាំទ្រផ្នួសតទៅទៀតបានទេ ហើយដែលពិតជាមានសិទ្ធិពេញទី នឹងសឹកបាន ( ព្រះពុទ្ធអនុញ្ញាតឲ្យសឹកបាន គ្រប់សង្ឃទាំងឡាយដែលពុំត្រូវការ ឬ ពុំអាចឋិតក្នុងភេទជាបព្វជិតតទៅទៀតបានទេ ) ។

— ខណៈ ទី ២ ( ទុំ - ទាវ ស្រឡាញ់គ្នាមុនពេលរៀបការ ) :

គឺជាទំនាស់កើតឡើងរវាងម្តាយទាវដែលប្រកាន់របប " ទំមិនធំជាងនាឡិ " ( លើកកូនឲ្យ ម៉ឺន - ងួន ដោយពុំបានទទួលការយល់ព្រមពីសាមីខ្លួនគេ ) ហើយនឹងទុំ - ទាវ ដែលការពារសិទ្ធិសេរីភាព ក្នុងការរៀបចំគ្រួសារផ្ទាល់របស់ខ្លួន ។

— ខណៈ ទី ៣ ( ទុំ - ទាវ ទូលការពិតចំពោះព្រះរាជា ) :

គឺជាទំនាស់រវាងព្រះរាជា ហើយនឹងទុំ - ទាវដែល ខំប្រយុទ្ធ ដើម្បីការពារនូវស្វាមីភក្តិ នឹងសេចក្តីបរិសុទ្ធរបស់ខ្លួន ។

## ផ្នែក ទី ២

គឺជាទំនាស់រវាង ម្តាយទាវ អរជូន ម៉ឺនងួន ( របបទំមិនធំជាងនាឡិ ឃោរឃៅ អត្តនិយម ) ហើយនឹង ទុំ - ទាវ ដែលនៅតែពុំព្រមចុះចាញ់ក្នុងការការពារសិទ្ធិស្របច្បាប់ នឹងកិត្តិយសរបស់ខ្លួន ។

## ផ្នែក ទី ៣

ពុំមានទំនាស់រវាង ទុំ ទាវ - នឹងអ្នកដទៃឡើយ ។

## ហេតុនៃទំនាស់

ក– ហេតុទី ១ បណ្ដាលមកពី ទុំ នឹង ទាវ ដែលការពារសិទ្ធិ នឹង កិត្តិយស របស់ខ្លួន ពុំព្រមចុះចាញ់ ។

ខ– ហេតុទី ២ បណ្ដាលមកអំពី :

១– សង្គមារម្មណ៍ :

– ជំនឿផ្ដេសផ្ដាស : ជឿការទាយទស្សន៍ (បើទុំសឹកនឹងត្រូវស្លាប់ ទំព័រ ២០ )

– ទំនៀមទំលាប់ផ្ដេសផ្ដាស : របបទំមិនធំជាងនាឡិ ( ទំព័រ ៤៥ - ៧១ )

២– អត្តនិយម :

ក– របស់ម្ដាយទាវ :

« . . ម្ដាយឲ្យទៅកូនចៅហ្វាយស្រុក បានសុខដោយបុណ្យដោយបានថ្កើង . . »
(ទំព័រ ៤៤ – ៧៤ – ៧៥ )

ខ– របស់អរជូន ម៉ឺនងួន : ដែលគិតតែពីសេចក្ដីសុខ សេចក្ដីចំរើនផ្ទាល់ខ្លួន ( ទំព័រ ៨៦ )

៣– អំពីឃោរឃៅ :

ក– របស់ម្ដាយទាវ :

ចាប់អាទុំចោរចិត្តមាន: ទាញពីលើផ្ទះទម្លាក់ទៅ. . . (ទំព័រ ៤៥–៧៥ នឹង ៩២ . . )។

ខ– របស់ អរជូន - ម៉ឺនងួន ដែល « ធម្មតាក្រោមមេឃទាបជាងក្ដី មានឫទ្ធិ អំណាចឥតដំនុំ កាប់ចាក់វាយដំពុំប្រណី » ហើយដែល « កន្ត្រាក់បានជាវស្ទុះចូលជុំ ចូលចាប់ចាក់កាប់ឥតដំនុំ . . . » ( ទំព័រ ៩៣ ) ។

## លក្ខណៈនៃទំនាស់

ហេតុផ្សេង ៗ នៃទំនាស់ដូចរៀបរាប់ខាងលើបញ្ជាក់ថា :

១– ជាទំនាស់ក្នុងបច្ចុប្បន្នជាតិ

២– ជាទំនាស់របស់មនុស្ស ចោទឡើងចំពោះយុវជន ២ រូបដែល ថ្វីត្បិតតែពុំមែនជាអ្នកប្រយុទ្ធដើម្បីជាតិមាតុភូមិក៏ដោយ ក៏ជាអ្នកត្រឹមត្រូវចេះស្គាល់ ស្រឡាញ់នឹងរក្សាសិទ្ធិសេរីភាព ហើយនឹងកិត្តិយសរបស់ខ្លួនឯងដែរ ។

៣– ទំនាស់ខាងលើទាំងនេះ មានកំរិតជាវិបត្តិតឹងតែងឡើង ៗ រហូតដល់ទៅមានសភាពជាទារុណភាព ( ក្នុងខណៈទី ៣ នៃផ្នែកទី ១ នឹងក្នុងផ្នែកទី ២ គេអាចសួរបានថា តើទុំ នឹងទាវស្លាប់ ឬពុំស្លាប់ ? ) ។

### ៣– បញ្ហាដោះស្រាយ

## ការដោះស្រាយ

ការដោះស្រាយក្នុងរឿងទុំទាវ គឺការប្រយុទ្ធគ្មានឈប់ឈរ ។ ការដោះស្រាយនេះឋិតនៅលើការទទួលយកកិត្តិយសមកធ្វើជាធំ ហើយដោយបោះបង់ចោលនូវប្រយោជន៍ជាទ្រព្យសម្បត្តិក្តី ឬជាបុណ្យសក្តិក្តី ។

## លក្ខណៈនៃការដោះស្រាយ

គឺជាការដោះស្រាយ ដោយយកកម្លាំងប្រឹងប្រែងផ្ទាល់ខ្លួនមកធ្វើជាមធ្យោបាយដែលជាមធ្យោបាយរបស់មនុស្សក្នុងលោកិយ ក្នុងបច្ចុប្បន្នជាតិ ពោលគឺពុំមានអន្តរាគមន៍នៃទេវៈណាឡើយ ។

ថ្វីត្បិតតែមតិខ្លះយល់ថារឿងទុំទាវ បានត្រូវនិពន្ធឡើងក្នុងគោលបំណងនឹងប្រដៅអ្នកអានឲ្យឃើញទោស នៃកាមតណ្ហាដែលអាចសម្លាប់មនុស្សដូចជាបានសម្លាប់ទុំនឹងទាវ

ក៏ដោយ ក៏ការសិក្សាបានបញ្ជាក់ផ្ទុយទៅវិញថា ទុំនឹងទាវពិតជាស្លាប់មកពីមនុស្សឃោរឃៅមួយចំនួន នឹងអារម្មណ៍ទូទៅនៃសង្គមមនុស្សក្នុងសម័យលង្វែកយ៉ាងនេះទៅវិញ ។

ដើម្បីបញ្ជាក់ការអះអាងខាងលើនេះ យើងនឹងលើកយកអត្ថរូបមកសិក្សាតទៅទៀត ។

## II. អត្ថរូប

### ក– និទានរូប

– រឿងទុំទាវជាអត្ថបទកាព្យពាក្យ ៧ ។

– និពន្ធតាមបែបប្រលោមលោក ។

តាមការស្រាវជ្រាវរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ក្រៅអំពីរឿងទុំទាវជាស្នាដៃរបស់ភិក្ខុសោម គេនៅបានប្រទះឃើញស្នាដៃមួយទៀតរបស់លោក នូ កន ដែលជាអត្ថបទកាព្យពាក្យ ៨ ហើយដែលមានចំណងជើងថា « ទាវឯក » ដូចនេះទៅវិញ ( បោះពុម្ព ១៩៤២ ) ។

រឿងទាវឯក បានបញ្ជាក់សេចក្ដីពិស្ដារច្រើន ដូចជាបញ្ជាក់ពីប្រវត្តិ ទុំ ទាវ នឹងអំពីទោសទុក្ខនៃអ្នកស្រុកត្បូងឃ្មុំជាដើមថែមទៀត ។

### ខ- បការរូប

ថ្វីត្បិតតែអ្នកនិពន្ធជាព្រះសង្ឃ ដែលមានទម្លាប់យក « ស្នេហា » ជាសត្រូវ ហើយដែលពោលក្នុងកន្លែងមួយថា « ទុំស្លាប់នេះខុសពីព្រោះស្រី » ក៏ដោយ ក៏អត្ថរូបទូទៅនៅតែបញ្ជាក់ថា មរណភាពនៃ ទុំ - ទាវ គឺពិតជាបណ្ដាលមកពីមនុស្សកាចមួយក្រុមនឹងសង្គមមនុស្ស ដូចរៀបរាប់ខាងនេលើះតែដដែល ។

យ៉ាងណាមិញ ពាក្យពេចន៍ ឃ្លាប្រយោគទាំងឡាយដែលរៀបរាប់ពីរូបសម្ផស្ស ពីប្រាជ្ញា ឬគសរសើរហើយសរសើរទៀត ពីសមត្ថភាពទុំ ពីការដែលអ្នកស្រុកត្បូងឃ្មុំនិយម

ស្រឡាញ់ទុំ . . . តើការសរសេរបែបនេះ មិនគឺដើម្បីបង្កើតសមានចិត្តរបស់អ្នកអាន ចំពោះរូបទុំទេឬ ?

ផ្ទុយទៅវិញ ពាក្យពេចន៍ ឃ្លាប្រយោគដែលនិយាយពីដំណើរចិត្តសាវ៉ា លោកលន់ របស់ម្តាយទាវ ដែលនិយាយពីលក្ខណៈរបស់អរជូនជាមនុស្ស «...ក្រោមមេឃ ទាបជាងក្អ មានឫទ្ធិអំណាចកាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី » ឬ ដែលបង្ហាញពីសកម្មភាពផ្តាច់ជីវិតទុំ តាមវិធីព្រៃផ្សៃអមនុស្សរបស់អរជូន ម៉ឺនងួន . . .

ទាំងនេះ តើពុំមែនជាកស្តុតាង បញ្ជាក់ថា បការរូបរឿងទុំទាវក៏ត្រូវបានតុបតែងឡើង ដើម្បីបំរើអត្ថន័យ ដែលមានបំណងនឹងបង្ហាញពីទោសទុក្រិដ្ឋរបស់ម្តាយទាវ អរជូន នឹង ម៉ឺនងួន ទេឬ ?

បើប្រសិនពុំមែនដូចនេះទេ តើអ្នកនិពន្ធមានប្រយោជន៍អ្វី នឹងហែកបង្ហាញមុខមាត់ដ៏កខ្វក់ អាក្រក់របស់ជនទាំងនេះ ឲ្យឃើញយ៉ាងច្បាស់ក្រឡែតយ៉ាងនេះ ?

ប៉ុន្តែកស្តុតាងសំខាន់ជាងគេ គឺបិតនៅក្នុងអន្តរូបនៃនិពន្ធរូបនេះឯង ។

## គ– និពន្ធរូប

### អារម្ភរូប

ដោយរឿងនេះជារឿងខ្មែរនិយម បានជាគេពុំប្រទះឃើញ « បច្ចុប្បន្នវត្ត » ដូចជាក្នុងរឿងជាតកនានាឡើយ ។

រឿងបានចាប់ផ្តើមបង្ហាញតួអង្គទុំ នៅក្នុងសង្គមបរិយាកាសមួយដ៏តឹងតែងតែម្តង ។

### អង្គរូប

រូបអ្នកនិពន្ធបានរៀបរាប់ដ៏ប៉ិនប្រសប់អំពីសេចក្តីស្នេហាទុំ - ទាវ ដែលវិវត្តពីខណៈ ១ ទៅខណៈ ១ ទៀត លើផ្លូវពោរពេញដោយឧបសគ្គ គ្រោះថ្នាក់ច្រើនប្រាងរហូតដល់ទៅប៉ះ

នឹងកំណាល់ទបសត្តធំជាចុងក្រោយបំផុត ដែលបង្កបង្កើតឡើងដោយម្ដាយទាវ អរជូន ម៉ឺនងួន ។

### អត្ថរូប

រឿងទុំ-ទាវពុំបានបញ្ចប់ត្រឹមមរណភាពនៃទុំ នឹង ទាវ ទេ ។ ប៉ុន្តែរឿងនេះនៅបានបន្តរហូតមកដល់ការកាត់ទោស សម្លាប់ម្ដាយទាវ អរជូន ម៉ឺនងួន នឹងបក្សពួកទៀតទើបចប់ ។

នេះគឺជាអត្ថរូបមួយ ដែលបញ្ជាក់ថា និពន្ធរូបបែបនេះពុំមានបំណងដាក់កំហុសលើទុំនឹងទាវឡើយ ។ បើប្រសិនជាការនិពន្ធមានបំណងចង់បញ្ជាក់ថា ទុំ-ទាវ មានកំហុសត្រូវស្លាប់ ព្រោះជាអ្នកលុះក្នុងកាមតណ្ហាមែន ការបញ្ចប់រឿងត្រឹមមរណភាពរបស់ទុំ នឹង ទាវ ជាការត្រឹមត្រូវ ។ បានជាត្រឹមត្រូវ ពីព្រោះឥឡូវនេះ ជនដែលគេយល់ថា មានកំហុសត្រូវស្លាប់នោះ បានទទួលទណ្ឌកម្មយ៉ាងជូរចត់ហើយ ។ ប៉ុន្តែ មិនដូចនេះទេ ជនដែលត្រូវទណ្ឌកម្មយ៉ាងជូរចត់ ត្រូវស្លារ ត្រូវពស់ក្បាលទាំងរស់នោះ បែរទៅជារូបម្ដាយទាវ អរជូន ម៉ឺនងួន នឹងអ្នករួមគំនិតដូចនេះទៅវិញសោះ ។

អត្ថន័យ អត្ថរូប ខាងលើបានធ្វើឲ្យរឿងទុំ - ទាវ មានតម្លៃពិសេសមួយរបស់ខ្លួន ក្នុងអក្សរសិល្ប៍ខ្មែរ ។

យើងនឹងលើកយកតម្លៃនេះ មកសិក្សាក្នុងផ្នែកអត្ថរសខាងក្រោមនេះ :

## III. អត្ថរស

### ក– បច្ចេករស

កាព្យរស le poètique

អត្ថបទពាក្យកាព្យពុំមែនសុទ្ធតែបង្កើតបាននូវកំណាព្យ ( កាព្យរស ) ទាំងអស់ទេ ។ កាព្យរសកើតមានបានដោយសារវូបារម្មណ៍វិធី ។

រឿងទុំទាវមានកាព្យរស ព្រោះមានរូបារម្មណ៍យ៉ាងសម្បូរណ៍ ដែលចិតនៅក្នុង :

— ពាក្យសំដី ( ជីវរូបារម្មណ៍ ) : រូបខ្ចីល្អក់ សម្លេងស្រួយស្រើប

— ឃ្លា ( ឧបមានរូបារម្មណ៍ ) ឧទា : ទំព័រ ៤៧ :

ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា ... កុំណា៎ខ្ញុំថាកុំសង្ស័យ ។

— ប្រយោគ ( រូបារូបិយារម្មណ៍ ) ឧទា : ទំព័រ ៥៥ :

- ការរៀបរាប់បង្ហាញទុក្ខព្រួយរបស់ទុំ ដែលអាចធ្វើឲយអ្នកអានទឹកឃើញ គិតឃើញច្បាស់ថាជាទុក្ខមែន ។

- ប្រយោគដែលរៀបរាប់ពណ៌នា អំពីទារុណកម្មលើរូបទុំ (អ្នកអានឃើញ ច្បាស់នឹងភ្នែកនូវការចងរុំ ហើយសាប់សុស ឲយចុះសាច់ដាច់សរសៃ ... ) ។

— អត្ថបទ. ( និមិត្តរូបារម្មណ៍ ) :

រឿងទាំងមូលបានបង្កើតនូវរូបភាព « អារម្មណ៍ » មួយផ្លុំង ដែល និយាយអំពីការតស៊ូពុំបានសម្រេចផលរបស់ ទុំ - ទាវ ជាហេតុនាំឲយអ្នកអានចាប់អារម្មណ៍ នឹកដល់ការរស់នៅក្នុងសង្គមមនុស្សសម័យលង្វែក ។

ប្រលោមរស

ប៉ុន្តែដោយរឿងទុំទាវ ជាអត្ថបទ ដែលមានការរៀបរាប់អធិប្បាយរបស់អ្នកនិពន្ធផង ( ឧទា : ស្ទុះរឿងទាវទៀតត្លៀតសំដែង... ទំព័រ ២៤ ) នឹងមានការសន្ទនារវាងតួអង្គ ផ្សេង ១ ផង ( ឧទា : ការសន្ទនារបស់ម្ដាយទាវ នឹង នាងទាវ - ទំព័រ ៤៤ ) បានជា រឿងនេះមានរសជាតិមួយទៀតជាប្រលោមរសនេះឯង ។

រសជាតិខាងលើទាំងនេះ ជារសជាតិកើតមកពីបច្ចេកវិធី នៃការតែងនិពន្ធ ។ តែអត្ថបទវែងជាពាក្យកាព្យ មានកាព្យរស ហើយបែបប្រលោមលោក មានប្រលោមរស ដូចគ្នានឹងរឿងទុំទាវនេះដែរ នៅមានតម្លៃពិសេសរបស់ខ្លួនផ្សេង ៗ គ្នា ដូចជា : កំសត់ កំប្លែង អស្ចារ្យ ( អតិស័យរស ) ជាដើមថែមទៀត ។

តើរឿងទុំទាវវិញមានវិសេសរសបែបណា ?

## ខ- វិសេសរស

### កំសត់រស

កំសត់រសនេះកើតមកពីការប្រយុទ្ធរវាងតួអង្គពីរក្រុម ដែលមានកម្លាំង នឹង លក្ខណៈមិនស្មើគ្នា :

— ក្រុមទី ១: គឺទុំនឹងទាវ ដែលមានកម្លាំងខ្សោយ ( តែពីរនាក់គត់ ) គ្មានអំណាច ប៉ុន្តែជាមនុស្សត្រឹមត្រូវស្លូតបូត ... ។

— ក្រុមទី ២: គឺសង្គមមនុស្ស អរជូន មុឺនងួន ម្ដាយទាវ ដែលជាអ្នកមានឫទ្ធិអំណាច ឥតដំនុំ ឃោរឃៅកាប់តាក់វាយដំគ្មានប្រណី ... ។

កំសត់រសកើតឡើង ដោយសារគេបានដឹងថា ទុំ-ទាវ ជាតួអង្គល្អគ្មានកំហុសអ្វីសោះ ក្រៅអំពីការពុំព្រមឲ្យគេរំលោភជាន់ឈ្លីលើសិទ្ធិសេរីភាព និងកិត្តិយសរបស់ខ្លួន ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏តួអង្គឃោរឃៅអាក្រក់ទាំងឡាយ នៅតែតាមធ្វើបាប ឈ្នានិះគ្មានឈប់ឈរ ។

កំសត់រសនេះ មានកំរិតកាន់តែខ្លាំងគួរកត់សំគាល់នៅត្រង់កន្លែង ដែលទុំត្រូវគេអូសទាញទម្លាក់មកដី ហើយចងក្រញឹតស្វិតស្វាបសេក ចាក់មុខបង្ហែតឥតគិតញាទ នឹងស្លាប់សុសធ្លុះសាប់ដាច់សរសៃនោះឯង ។

ផ្ទុយទៅវិញ ម្ដាយទាវ អរជូន ម៉ឺនជួន ដែលត្រូវស្មោរ ត្រូវកប់ក្បាលទាំងរស់នោះ ពុំបានបង្កើតនូវ កំសត់នេះឡើយ ពីព្រោះតួអង្គទាំងនេះជាតួអង្គឃោរឃៅ មានកំហុស នឹងគុណវិបត្តិផ្សេង ៗ ទៀតច្រើនយ៉ាងណាស់ ។

ហេតុនេះ បើរឿង ទុំទាវ និយាយពីទោសកំហុសនៃទុំនឹងទាវ (ទោសកាមតណ្ហាមែន) តើហេតុអ្វី បានជាអ្នកអានបែរជាទៅកំសត់អាណិត ទុំ នឹង ទាវ ហើយចង់កំហឹងខឹងនឹងម្ដាយទាវ អរជូន ម៉ឺនជួន ដូចនេះទៅវិញ ?

## គ- សច្ចរស

ប៉ុន្តែរឿង ទុំ-ទាវ ដែលបានគេចផុតពីជំនឿសាសនា ពីមនោគតិទេវកាយ ហើយបានលើកយករឿងមនុស្សមកចោទជាបញ្ហា នឹងដោះស្រាយបែបនេះ មានតម្លៃទៅមួយគឺ : មនុស្សរស ។

យ៉ាងណាមិញ មនុស្សរសនៃរឿង ទុំទាវ ឋិតនៅលើ :

តួអង្គ : ជាមនុស្ស ជាខ្មែរ ( ទុំ ទាវ អរជូន... ពោលគឺគ្មាន ពោធិសត្វ ឬ ទេវៈ យក្សមារណាឡើយ ) ។

ទីកន្លែង : ឋានមនុស្ស ស្រុកខ្មែរ ( លង្វែក ត្បូងឃ្មុំ ពោលគឺគ្មានឋានសួគ៌ ឋាននរក បាតាល . . . អ្វីឡើយ ) ។

ដំណើររឿង : ជារឿងមនុស្សដែលខំកសាងសុភមង្គលមិនសម្រេច ព្រោះការបៀតបៀនឈ្នានិះរបស់មនុស្សគ្នាឯង ដែលជាមនុស្សឃោរឃៅ ពោលគឺពុំមែនជារឿងកើតមកពីកម្មពៀរជាតិមុនជាតិក្រោយ ហើយដោះស្រាយរួចវិញ ដោយសារអន្តរាគមន៍របស់ទេវៈ : ខ្មោចខ្មាំង យក្សយម ព្រហ្មប្រេតឯណាមួយឡើយ ។

ប៉ុន្តែ ពិសេសជាងនេះទៅទៀត រឿងទុំទាវ ដែលបានលើកយករឿងមនុស្សមកនិយាយយ៉ាងនេះហើយ នៅបានអធិប្បាយបង្ហាញការពិត បង្ហាញកិនភាគមុខមាត់នៃសង្គមមនុស្សយ៉ាងណាយ៉ាងនោះ — ជាហេតុនាំឲ្យមានតម្លៃ រសជាតិមួយសំខាន់ទៀតគឺ តជ-រស នេះឯង ។

## សេចក្ដីសន្និដ្ឋាន

បើប្រៀបធៀបទៅនឹងរឿងដទៃទៀត កើតឡើងក្នុងសម័យជាមួយគ្នា ដែលសុទ្ធសឹងតែថិតនៅក្រោមឥទ្ធិពលនៃជំនឿ សាសនា ទឹងមនោគតិវើរវាយ គេអាចចាត់រឿងទុំទាវ ដែលនិយាយពីការពិត តថភាពនៃសង្គមខ្មែរសម័យលង្វែក ហើយដែលប្រកបទៅដោយអត្ថរូបស្រស់ល្អនេះ ថាជាស្នាដៃពិសេសមួយក្នុងអក្សរសិល្ប៍ខ្មែរយើង ។

NOUVELLE REVUE PEDAGOGIQUE (bimensuel)
Fernand Nathan et Cie,
18, Rue Monsieur le Prince, Paris 6e

L'ECOLE DES PARENTS (mensuel)
47, Rue de Miromesnil, Paris 8e

L'ECOLE LIBÉRATRICE (bihebdomadaire)
94, Rue de l'Université, Paris 7e



• ... ពីវិទ្យាល័យ រាស្ត្រនិយមព្រះសីហនុ (តាខ្មៅ)

កាលពីថ្ងៃ៩ កុម្ភៈ១៩៦៦ សាស្ត្រាចារ្យនឹងបុគ្គលិកចំនួន ២១៨ នាក់នៃអនុវិទ្យាល័យទាំងអស់ក្នុងខេត្តកណ្ដាល គឺអនុវិទ្យាល័យដីឥដ្ឋ - កោះធំ - ជម្ពូវ័ន - រកាកោង - ព្រែកអញ្ចាញ - ផ្សារថ្មី - ស្អាង - ទឹកឃ្លាំង បានចូលមករួបរួមប្រកួតជាមិត្តភាពនូវកីឡាបាល់ទះ នឹងកីឡាកូនឃ្លីលើតុ នៅក្នុងវិទ្យាល័យរាស្ត្រនិយមព្រះសីហនុ ក្រុងតាខ្មៅ ។

តាំងពីច្រើនថ្ងៃមុនពេលប្រកួតម៉្លេះ មិត្ត ស៊ឹម ហុង នាយកវិទ្យាល័យបានធ្វើការប្រជុំសាស្ត្រាចារ្យ នឹងបុគ្គលិក ដើម្បីចែកការផ្សេងៗ ។ សាស្ត្រាចារ្យខ្លះទទួលភារៈខាងទទួលភ្ញៀវ ខ្លះខាងម្ហូបអាហារ ឬ ភេសជ្ជៈ ខ្លះជាអ្នកបំរើភ្ញៀវ ហើយខ្លះទៀតជាអ្នកធ្វើកម្មវិធី នឹងរៀបចំទីលានប្រកួត ។ សិស្សានុសិស្សមួយចំនួនធំ ក៏បានឈឺឆ្អាលចំពោះការងារគ្រូរបស់ខ្លួនដែរ ។ គេជួយលើកដាក់ ជួយរៀបចំកៅអី បោសសំអាត ជួយចំអិនអាហារ នឹងជួយបំរើភ្ញៀវគ្រប់ៗគ្នា ។

ថ្ងៃប្រកួតមកដល់ហើយ ។ ព្រឹកនេះ វិទ្យាល័យតាខ្មៅមានបរិយាកាសប្លែកពីប្រក្រតីៗ គណៈកម្មការខាងបដិសណ្ឋារកិច្ចបានមកដល់សាលា តាំងពីព្រលឹមម៉្លេះ ដើម្បីរង់ចាំទទួលភ្ញៀវ ដែលមកដល់ជាលំដាប់លំដោយ ។



ពេលបាយថ្ងៃត្រង់ ក្រោយការប្រកួតលើកទី ១

ម៉ោង ៧ បាយហើយ ៗ ទីលានវិទ្យាល័យ ក៏ពេញទៅដោយកីឡាករ ដែលមានសំលៀកបំពាក់ប្លែកៗ ហើយដែលកំពុងតែចាប់ដៃគ្នា សំណេះសំណាលសួរសុខទុក្ខ ញញឹមញញែមដាក់គ្នា ៗ

ម៉ោងជាង ៨ កីឡាករទាំងអស់ក៏នាំគ្នាឈរជាជួរតាមសាលារៀន ៗ ខ្លួន ដើម្បីរង់ចាំធ្វើគារវកិច្ចចំពោះលោកអភិបាលខេត្តដែលបានអញ្ជើញមកទស្សនាកំសាន្តនឹងជាកិត្តិយសៗ

ក្រោយពីសុន្ទរកថារបស់សាស្ត្រាចារ្យជាតំណាងម្នាក់មក ការប្រកួតក៏ចាប់ផ្ដើម ៗ ប៉ុន្តែដោយក្រុមកីឡាមានច្រើន ការប្រកួតក៏ត្រូវបញ្ឈប់មួយលើកនៅពេលថ្ងៃត្រង់ ដើម្បីទុកពេលឲ្យមិត្តយើងទទួលទានបាយនឹងសំរាក ៗ

ម៉ោង ២ រសៀល ការប្រកួតក៏ចាប់ផ្ដើមម្ដងទៀត ៗ ម្ដងនេះ គឺជាការប្រកួតដ៏ស្វិតស្វាញនឹងល្អមើលខ្លាំងឡើង ៗ ព្រោះជាការប្រកួតរវាងដៃគូ នឹងក្រុមឈ្នះៗ ៗ លុះដល់ល្ងាចត្រជាក់ទើបការប្រកួតបានចប់សព្វគ្រប់ ដោយលទ្ធផលដូចខាងក្រោមនេះ :

ក— កីឡាបាល់ទះ

— លេខ ១ : ក្រុមអនុវិទ្យាល័យ ដីឥដ្ឋ
— លេខ ២ : ក្រុមវិទ្យាល័យ តាខ្មៅ
— លេខ ៣ : ក្រុមអនុវិទ្យាល័យ រកាកោង

១– កីឡាកូនឃ្លី

— លេខ ១ : មិត្ត ទូច សេងហួ ( អនុវិទ្យាល័យ ព្រែកតាមាក់ )

— លេខ ២ : មិត្ត ឋាច់ អ៊ិញ ( អនុវិទ្យាល័យ ដីឥដ្ឋ )

គេទាំងឡាយបានបែកគ្នា ដោយសេចក្ដីអាល័យយ៉ាងខ្លាំង ហើយបានមត់ថា នឹងជួបគ្នាជាថ្មីម្ដងទៀតនៅអនុវិទ្យាល័យជម្ពូវ័ន ដើម្បីប្រកួតកីឡាបាល់ទោះ ។

ដោយ៖ កីឡាមិត្តភាព !

## • ... ពីអនុវិទ្យាល័យ ស្មើសោភ័ណ ( កំពង់ចិន )

នៅរសៀលថ្ងៃសៅរ៍ ទី ១៩ កុម្ភៈ ១៩៦៦ គេអាចសង្កេតឃើញ សភាពអ៊ូអរប្លែកពីធម្មតា នៅក្នុងបរិវេណអនុវិទ្យាល័យ ស្មើសោភ័ណ ។ សិស្សានុសិស្សជាច្រើន ព្រមទាំងបុគ្គលិកទាំងអស់នៃអនុវិទ្យាល័យ បានមកជួបជុំគ្នាជាស្រេច ដើម្បីរង់ចាំទទួលគណៈប្រតិភូក្រុមកីឡា បុគ្គលិកអនុវិទ្យាល័យ សម្ដេចព្រះឧបយុវរាជ កំពង់ក្ដី (សៀមរាប) ដែលត្រូវអញ្ជើញមកដល់នៅម៉ោង ២ កន្លះ ។

មិត្តចាងហ្វាងព្រមទាំងបុគ្គលិកមួយចំនួន បានចេញមកពាក់ទាក់ ទទួលភ្ញៀវតាំងអំពីក្លោងទ្វារ ។ ទាំងពាក្យសំដី ទាំងកាយវិការ សុទ្ធតែបញ្ជាក់នូវសេចក្ដីនឹករលឹក ការរាប់អានដោយស្មោះស្ម័គ្រ និងមិត្តភាពដ៏វែងប៉ុង ។ គេចាប់ដៃគ្នាយ៉ាងណែន គេសាកសួរសុខទុក្ខគ្រួសារ ស៊ើបសួរអំពីដំណើរការនៃអនុវិទ្យាល័យ អំពីសហករណ៍សិក្សា គេចំអែចអន់គ្នា គេកៀកកកៀកស្មាគ្នា គេសប្បាយរីករាយនឹងការជួបគ្នានេះមែន ! មិត្តចាងហ្វាងអនុវិទ្យាល័យស្ពានស្មើ បានណែនាំមិត្តជាភ្ញៀវទាំងអស់ ឱ្យស្គាល់សហករណ៍នៅអនុវិទ្យាល័យ ហើយនៅបានបញ្ជាក់ថា គណៈកម្មាធិការ យ.វ.ស.វ នៃអនុវិទ្យាល័យ នឹងរៀបចំពិធីបោះជំរុំនៅពេលល្ងាចនោះឯងផង ។

ការប្រកួតកីឡាបានចាប់ផ្ដើមនៅម៉ោង ៣ គត់ ។ ដោយនិយមថា ការឈ្នះចាញ់ត្រូវទុកជាបន្ទាប់បន្សំ គេឃើញមិត្តចាន់ហ្វាំងទាំងពីរបើកឆាកជាកិត្តិយស នូវការប្រកួតកីឡាកូនឃ្លីលើតុ ដែលបានចប់សព្វគ្រប់ ដោយលទ្ធផលស្មើគ្នា គឺឈ្នះ ២ ចាញ់ ២ ។ បន្ទាប់មកគឺការប្រកួតកីឡាបាល់ទះ ។ ដោយមានសមត្ថភាពប្រហាក់ប្រហែលគ្នា ការប្រកួតក៏មានសភាពស្វិតស្វាញ ហើយត្រូវបានទាញបន្ទាយអស់ពេលយ៉ាងយូរ ។ ជ័យជំនះក៏ត្រូវបានទៅក្រុមកីឡាអនុវិទ្យាល័យកំពង់គ្គី ដោយលទ្ធផល ៣ ទល់នឹង ២ ។

ក្រោយការប្រកួត មិត្តទាំង ២ ក្រុម បានសន្ទនាគ្នាយ៉ាងស្និទ្ធស្នាល ហើយសន្យាថានឹងបានជួបគ្នាទៀត ក្នុងពេលអនាគតដ៏ខ្លី នៅអនុវិទ្យាល័យ កំពង់គ្គីម្ដងវិញ ។ ក្រុមអនុវិទ្យាល័យជាភ្ញៀវបានចេញពីអនុវិទ្យាល័យស្ទោង នៅម៉ោង ៥ កន្លះ ដោយអាលោះអាល័យ ក្រោមសូរទះដៃជូនដំណើរ អំពីសំណាក់សិស្សានុសិស្សជាច្រើន ។

សូមបញ្ជាក់ថា មិត្តចាន់ហ្វាំងអនុវិទ្យាល័យកំពង់គ្គី ព្រមទាំងមិត្តមួយចំនួនទៀត ត្រូវបានអញ្ជើញឲ្យចូលរួមពិធីបោះជំរុំរហូតដល់ពេលចប់ពិធី នៅម៉ោង ១០ កន្លះ ។

លុះដល់មកថ្ងៃទី ១០ មីនា ១៩៦៦ ដូចដែលបានសន្យា ការប្រកួតកីឡារវាងក្រុមអនុវិទ្យាល័យទាំង ២ ក៏បានប្រព្រឹត្តទៅម្ដងទៀត នៅអនុវិទ្យាល័យ សម្ដេចព្រះឧបយុវរាជ កំពង់គ្គី ( សៀមរាប ) ។

ម៉ោង ២ គត់ ក្រុមកីឡាមិត្តអនុវិទ្យាល័យ ស្ទោសោភ័ណ កំពង់ចិន បានមកដល់ស្រេច ។ ការប្រកួតដែលប្រកបដោយបរិយាកាសយ៉ាងស្និទ្ធស្នាលជាទីបំផុត បានចាប់ផ្ដើមនៅម៉ោង ៣ គត់ ហើយបានចប់សព្វគ្រប់នៅម៉ោង ៥ កន្លះ ។ លទ្ធផលគឺ ៖

— បាល់ទះ :

អនុវិទ្យាល័យកំពង់គ្គី ឈ្នះអនុវិទ្យាល័យកំពង់ចិន ៣ ទល់នឹង ២

— កូនឃ្លីលើតុ :

អនុវិទ្យាល័យ កំពង់គ្គី ឈ្នះ ៣ ទល់នឹង ១

## • . . . ពីវិទ្យាល័យ សន្តិភាព (កំពង់ស្ពឺ)

ថ្ងៃអាទិត្យ ២៧ – ២ – ៦៦ មានសភាពអ៊ូអរប្លែកធម្មតា នៅក្នុងបរិវេណវិទ្យាល័យ សន្តិភាព ព្រោះថ្ងៃនេះយើងត្រូវទទួលក្រុមកីឡា មិត្តសាស្ត្រាចារ្យមកពីវិទ្យាល័យ ពញាយ៉ាត ។

ម៉ោង ៨ ទៅហើយ យើងចាំមិត្តយើងយ៉ាងអន្ទះអន្ទែង ។ មួយស្របក់ស្រាប់តែសូរ ទះដៃលាន់ឮព្រាវឡើង ។ ហេ ! ហេ ! មិត្តយើងមកដល់ហើយ ! យើងនាំគ្នាស្ទុះស្រូចូលទៅចាប់ដៃសួរសុខទុក្ខមិត្តយើងទាំងអស់គ្នា ។ មិត្តខ្លះលាន់មាត់ថា យី ! គ្នាចាំមើលផ្លូវស្ទើរស្លាប់ទៅហើយ មិត្តអើយ ។ ក្រុមកីឡាខាងវិទ្យាល័យពញាយ៉ាតមានគ្នាម្ភៃប្រាំនាក់ ដឹកនាំដោយមិត្ត អ៊ុន រុំ នាយកវិទ្យាល័យ ។ ក្រោយពីបានសួរនាំគ្នារួចហើយ មិត្តយើងក៏ចាប់ប្រកួតបាល់ទះ ។ ជ័យជំនះបានទៅខាងមិត្តវិទ្យាល័យ សន្តិភាព ។ ឯការប្រកួតបាល់បោះ ក៏ចាប់ផ្តើមជាបន្តបន្ទាប់មកទៀត ។ ម្តងនេះ មិត្តវិទ្យាល័យពញាយ៉ាតឈ្នះម្តងវិញ ។

លុះចប់ការប្រកួតហើយ យើងក៏នាំគ្នាទៅវត្តគ្រួសជាទីសំរាកកំសាន្តមួយល្បីឈ្មោះដែរ ។ នៅទីនោះ មិត្តយើងរៀបចំចាំទទួលយ៉ាងពក់ចាក់កក់ក្តៅ ។ បន្ទាប់ពីថ្ងៃងសេចក្តីស្និទ្ធស្នាលរួចមក មិត្តយើងនាំគ្នាលេងទឹក លុះអស់ចិត្ត ទើបនាំគ្នាពយវង់បាយ ក្រោមម្លប់ដើមឫស្សីយ៉ាងត្រជាក់រហឹម ។ យើងស្និទ្ធស្នាលគ្នាណាស់ ឥតប្រកាន់ឋានៈថា អ្នកនេះជានាយក អ្នកនោះជាសាស្ត្រាចារ្យ អ្នកនេះជាអនុរក្ស អ្នកនេះជាស្មៀន អ្វីឡើយ ។ យើងញុំាបាយបណ្តើរ និយាយគ្នាលេង ពីនេះ ពីនោះ បណ្តើរ តែប្រធានដែលយើងចាប់អារម្មណ៍ជាងគេ គឺការកែប្រែកម្មវិធីសិក្សា ។ មិត្តយើងច្រើនតែយល់ស្របគ្នាថា សំខាន់គឺត្រូវធ្វើយ៉ាងណាឲ្យតែការសិក្សាយើងបាញ់ឆ្ពោះទៅបំរើកិច្ចការបង្កើតផលិតផល ។

ពេលរសៀលម៉ោង ៣ យើងក៏ចាប់លាគ្នាទាំងស្តាយ តែយើងសន្យាគ្នាថា ថ្ងៃណាមួយ យើងនឹងបានជួបគ្នាទៀតមិនខាន ។

បន្ទាប់ពីបានទទួលមិត្តវិទ្យាល័យពញាយ៉ាត នៅថ្ងៃអាទិត្យ ៦ –៣– ៦៦ វិទ្យាល័យសន្តិភាពយើង ក៏បានទទួលក្រុមកីឡា មិត្តមកពីអនុវិទ្យាល័យគងពិសីថែមទៀត ។ យើងបានរៀបចំទទួលមិត្ត គងពិសី ដូចកាលដែលយើងបានទទួលមិត្តវិទ្យាល័យពញាយ៉ាតដែរ ។ ឯបរិយាកាសមិត្តភាពវិញ ក៏ឃើញថា មិនចាញ់លើកមុនដែរ ។ គួរកត់សំគាល់ថា មិត្តអនុវិទ្យាល័យគងពិសី មានគ្នាតិចមែន តែមានមិត្តអ្នកកីឡាចំណាប់ចំនួនណាស់ បានឈ្នះកីឡាបាល់ទះ មិត្តវិទ្យាល័យសន្តិភាព យ៉ាងអង់អាច ។

## ● . . . ពីអនុវិទ្យាល័យ ព្រៃដើមថ្នឹង

នៅថ្ងៃទី ១០ កុម្ភៈ ១៩៦៦ មានការប្រកួតកីឡាបាល់ទះ ដើម្បីប្តូរតិចនិច នឹងកលល្បិច រវាងក្រុមយុវសិស្សអនុវិទ្យាល័យព្រៃដើមថ្នឹង នឹងក្រុមសហកីឡាបុគ្គលិកសិក្សាស្រុកស៊ីធរកណ្តាល ដែលនឹងត្រូវទៅប្រកួតជាមួយក្រុមបម្រុះកំពង់ចាម ។

ក្នុងថ្ងៃនេះ ជ័យជំនះនៃប្រកួតដែលមានពីរលើក ត្រូវធ្លាក់ទៅលើក្រុមយុវកីឡាអនុវិទ្យាល័យព្រៃដើមថ្នឹងទាំងអស់ ។

## ● . . . ពីវិទ្យាល័យ ព្រះគន្ធបុប្ផា

កាលពីថ្ងៃអាទិត្យទី ១៣ កុម្ភៈ ១៩៦៦ បុគ្គលិកវិទ្យាល័យព្រះគន្ធបុប្ផា បានធ្វើដំណើរទៅប្រកួតកីឡាជាមិត្តភាព ជាមួយបុគ្គលិកអនុវិទ្យាល័យ តាំងគោក ។

មិត្តនៅតាំងគោក បានទទួលមិត្តយើងយ៉ាងកក់ក្តៅរីករាយជាទីបំផុត ។

យើងបានប្រកួតកីឡា ៤ មុខ គឺបាល់ទះ បាល់បោះ កូនឃ្លីលើតុ នឹងបាល់ទាត់ ។ យើងចាប់ប្រកួតតាំងពីម៉ោង ៨ ព្រឹក សំរាកពេលបាយ ហើយបន្តរហូតព្រលប់ ។

លុះដល់ថ្ងៃអាទិត្យទី ១៣ មិនា ១៩៦៦ មិត្តបុគ្គលិកអនុវិទ្យាល័យ តាំងគោក បានអញ្ជើញមកប្រកួតកីឡានៅវិទ្យាល័យព្រះគន្ធបុប្ផាវិញ ។

មិត្តយើងក៏រៀបចំទទួលភ្ញៀវវិញ ក្នុងបរិយាកាសស្និទ្ធស្នាលជាអនេក ។

យើងយល់ថា ការប្រកួតកីឡានេះជាឱកាសធ្វើឲ្យយើងបានទាក់ទង ស្គាល់គ្នាជាថ្មីទៀត នឹងជាកត្តាជួយរឹតចំណងមិត្តភាព នឹងសាមគ្គីភាពរវាងបុគ្គលិកនៅគ្រឹះស្ថានមធ្យមសិក្សាទាំងពីរនេះ ហើយនឹងអាចប្ដូរបច្ចេកទេសគ្នាទៅវិញទៅមកផង ។ រីឯលទ្ធផលវិញ ទាំងពីរលើក គឺស្មើគ្នា ឈ្នះពីរមុខ ចាញ់ពីរមុខ ។

★

កាលពីថ្ងៃអាទិត្យទី ៦ មិនា ១៩៦៦ បុគ្គលិកសកលវិទ្យាល័យភូមិន្ទ កំពង់ចាម បានអញ្ជើញមកប្រកួតកីឡាជាមួយបុគ្គលិកវិទ្យាល័យព្រះគន្ធបុប្ផា នៅក្នុងបរិវេណវិទ្យាល័យព្រះគន្ធបុប្ផា ។

មិត្តយើងនៅព្រែកទឹងបានរៀបចំទទួលយ៉ាងឧឡារិក ។ ការប្រកួតមានធ្វើតែមួយព្រឹកទេ ( ប្រកួត ២ មុខ គឺ បាល់ទះ នឹងបាល់ទាត់ ) ។ ដោយមិត្តនៅសកលវិទ្យាល័យចង់អញ្ជើញទៅលេងទឹកធ្លាផង ក្នុងឱកាសនោះ មិត្តនៅវិទ្យាល័យព្រះគន្ធបុប្ផា ក៏ទៅរៀបចំទទួលបាយនៅឯទឹកធ្លាតែម្ដង ។ មិត្តយើងទាំងអស់បាននៅសំរាកកំសាន្តលេងឯទឹកធ្លារហូតដល់ល្ងាចត្រជាក់ ។

លុះដល់ថ្ងៃអាទិត្យទី ២០ មិនា ១៩៦៦ មិត្តបុគ្គលិកវិទ្យាល័យព្រះគន្ធបុប្ផា ក៏បានអញ្ជើញទៅប្រកួតជាមួយមិត្ត នៅសកលវិទ្យាល័យភូមិន្ទកំពង់ចាមវិញ ។ មិត្តសកលវិទ្យា-ល័យប៉ិនប្រសប់រៀបចំទទួលភ្ញៀវណាស់ ។

ប្រកួតពីរមុខ : កូនឃ្លីលើតុ នឹង បាល់ទះ ។ ការប្រកួតបានធ្វើតែមួយពេលល្ងាចរួចហើយនៅពេលព្រលប់ មិត្តនៅសកលវិទ្យាល័យបានធ្វើពិធីជប់លៀងមួយយ៉ាងគ្រប់គ្រាន់ ជាកិត្តិយសដល់មិត្តវិទ្យាល័យព្រះគន្ធបុប្ផានៅផ្ទះចិន ។

យើងបានសង្កេតឃើញថា ការប្រកួតកីឡាទាំងពីរលើកនេះ នាំឲ្យយើងបានស្គាល់រាប់អានគ្នាយ៉ាងរាក់ទាក់ជាទីបំផុត ។ នេះជាចំណងមិត្តភាពរវាងមធ្យមសិក្សា និងឧត្តមសិក្សានៅក្នុងខេត្តកំពង់ចាម ។ ម្យ៉ាងទៀត មិត្តយើងទាំងអស់បានលាន់មាត់ជាពិសេស ចំពោះការរីកចំរើនយ៉ាងឆាប់រហ័សខាងបច្ចេកទេស ក្នុងការលេងកីឡាបាល់ទះរបស់ក្រុមទាំងពីរ ។

★

## ស្មារតីជួយឈឺឆ្អាលដល់មិត្ត ដែលទទួលរងគ្រោះ

នៅពេលរៀបចំទទួលមិត្តបុគ្គលិកសកលវិទ្យាល័យភូមិន្ទកំពង់ចាម មិត្តយើងបានទទួលគ្រោះថ្នាក់មួយដ៏ចម្លែក ។ មិត្តយើង ៤ នាក់ ដែលជិះឡានតូបផ្ទាល់ខ្លួនរបស់មិត្ត ហួង ប៉េងឈារ ដើម្បីស្វះស្វែងរកទិញគ្រឿងនឹងបន្លែ ស្រាប់តែត្រូវទទួលគ្រោះថ្នាក់ដោយសារមែកពោធិដ៏ធំមួយបាក់សង្កត់មកលើឡាន ។ សំណាងល្អ ! មិត្ត ៤ នាក់នោះបានគេចរួចពីមរណភាព គ្រាន់តែត្រូវរបួសក្បាលមិត្តម្នាក់តែប៉ុណ្ណោះ ។

គ្រាន់តែទទួលដំណឹងនេះភ្លាម មិត្តបុគ្គលិកទាំងអស់ ក៏ម្នីម្នាទៅជួយខ្នះខ្នែងដល់ទីកន្លែងគ្រោះថ្នាក់ ។ ឡានត្រូវខូចខាតជាដំណំ ។

រំលង ២–៣ ថ្ងៃក្រោយមក ដើម្បីជួយរំលែកទុក្ខ ដែលត្រូវធ្លាក់ធុន់ទៅលើមិត្ត ហួង-ប៉េងឈារ មិត្ត ឈិន-នឹម នាយកវិទ្យាល័យ បានប្រមូលប្រជុំបុគ្គលិកវិទ្យាល័យទាំងអស់ក្នុងគោលបំណងរិះរកមធ្យោបាយណា ជួយសម្រាលការខាតបង់របស់សហការីមួយរូប ។

ក្រោយពីលោកនាយកប្រកាសបើកសម័យប្រជុំ និងលើកបញ្ហានេះមក មិត្តជាច្រើនបានស្នើឲ្យមិត្តយើងជួយចេញភាគទានជាប្រាក់កាស តាមការស្ម័គ្រ ។ អង្គប្រជុំបានសំរេចជាឯកច្ឆន្ទ ជួយចេញក្នុងម្នាក់ ៗ មានតាំងពី ២០០៛ រហូតដល់ ៥០០៛ ។

មិត្តនាយកដែលមានការរំភើបចិត្តជាពន់ពេក ចំពោះកាយវិការនេះ បានសំដែងនូវអំណរគុណដែលពុំអាចបំភ្លេចបានដល់សហការីទាំងអស់ ព្រមទាំងបញ្ជាក់ថា នេះបានពិតជាស្មារតីសាមគ្គីភាពដ៏រឹងប៉ឹងមែន !

# ស្វាគមន៍មិត្តថ្មី

● យើងទើបនឹងបានទទួលដំណឹងដ៏រីករាយ អំពីពិធីរៀបអាពាហ៍ពិពាហ៍នៃ :

| | | | |
|---|---|---|---|
| មិត្ត | អ៊ុំ គឹមអេង | ជាគូនឹងកញ្ញា | ឃៀវ សំទក |
| — | ឈៀវ អីវកាំង | — | ហុង គឹមសែ |
| — | នន់ នាក់ | — | ប្រាក់ សោភ័ណនី |
| — | កង ម៉ុន | — | ប៉ាល់ សៅផលី |
| — | ឈឿង វ៉េងហួង | — | ឈួ អេងស្រ៊ាង |
| — | បៅ អ៊ិច | — | ម៉ង្គ កួងមាល័យ |
| — | អ៊ុក អ៊ុម | — | កៅ ជិនណាង |
| — | អ៊ុម ក៉ន់ថា | — | គឹម យ៉េត |
| — | ដួង សុខសាន្ត | — | ម៉ិន ទីស៊ាន |
| — | តាន់ គឹមពាន | — | នាង យុងវិន |
| — | ជា ឈុន | — | ឃុន យ៉េកស៊ិន |
| — | សរ ហៃសែម | — | ជា ស៊ុនី |
| — | ព្រាប ទួន | — | ខៀវ ជួក |
| — | តិក ពុយ | — | ជ័យឥន្ទុតាពបទុ |
| — | តាំង ធុងហួត | — | លី គឹមអ៊ាង |
| — | ជៀន ជូហ៊ុ | — | អ៊ាប ឡាំងនាង |

ក្នុងពិធីទាំងប៉ុន្មាននេះ ស្ទើតែមានសមាជិកគ.នាយក ឬ មិត្តតំណាង ស.ស.ខ យើងចូលរួមទាំងអស់ ។

សូមប្រសិទ្ធិពរជ័យវរ ចំពោះគូស្រករទាំងអស់ខាងលើឲ្យបានជួបតែនឹងជោគជ័យ សិរីមង្គលក្នុងជីវភាពថ្មី កុំបីឃ្លៀងឃ្លាតឡើយ ។

● កាលពីថ្ងៃ ២៧ មករានេះ មិត្ត លី គឹមអ៊ី ជាតំណាង ស.ស.ខ ប្រចាំអនុវិទ្យាល័យទេពប្រណម្យ នឹងភរិយារបស់មិត្ត បានធ្វើកាយវិការដ៏ប្រសើរមួយ ដោយបានទទួលយកបុត្រអាយុ ២ ថ្ងៃ កំព្រាមាតា នៃលោកសំរិត បូ លេខាធិការគណៈកម្មការពង្រីកការសិក្សា ដែលមានកូនតូច ៗ ក្នុងបន្ទុករហូតដល់ទៅ ៥ នាក់ទៅហើយ ។

មិនតែប៉ុណ្ណោះ ថ្ងៃក្រោយបន្តិចមក សមាជិក ស.ស.ខ ទាំងអស់នៃអនុវិទ្យាល័យបានចាត់មិត្ត កាន់ វ៉ន ជាតំណាងវេង ឲ្យទៅប្រសិទ្ធិពរដល់មិត្ត នឹងភរិយា ដែលទើបនឹងក្លាយជាបិតាមាតានៃបុត្រថ្មីនេះ ។

ថែមពីលើនេះទៅទៀត ដំណឹងល្អ ៗ ពីអនុវិទ្យាល័យខាងលើនៅតែបានហូរមកដល់យើងគ្មានឈប់ឈរ ។ នេះគឺដំណឹងអំពីមិត្ត គង់ ង៉ែត នឹងមិត្ត ស៊ូ ស៊ុថុង ដែលទើបនឹងក្លាយរៀង ៗ ខ្លួនជាបិតាដំបូងបំផុត ។

នៅក្នុងអនុវិទ្យាល័យនេះ សាមគ្គីភាពមានសភាពរឹងប៉ឹងណាស់ ។ គេនាំគ្នាចែករំលែកសេចក្ដីសុខ ក៏ដូចជាជួយរំលែកសេចក្ដីទុក្ខ ដែលកើតឡើងចំពោះមិត្តណាម្នាក់ដែរ ។ ហេតុនេះហើយបានជាមិត្តយើងទាំងឡាយ បាននាំគ្នាវែបច្ច័យនឹងចូលរួមរំលែកមរណទុក្ខរបស់មិត្ត ម៉ម សារឹម ដែលទើបនឹងបាត់បង់មាតាកាលពីខែមុន ។

ដោយនៅឆ្ងាយពុំមានលទ្ធភាពនឹងជួបផ្ទាល់បាន យើងទាំងអស់គ្នាជាសមាជិក គ.នាយក សូមមិត្ត ម៉ម សារឹម ទទួលនូវសេចក្ដីក្រៀមក្រំមចិត្តរបស់យើង ដែលសូមចូលកាន់មរណសញ្ញាជាមួយមិត្តផងដែរ ។

សកម្មភាពដ៏ថ្លៃថ្លាទាំងប៉ុន្មានខាងលើរបស់ មិត្តតំណាង មិត្តតំណាងរងនិងមិត្តសមាជិកទាំងអស់ នៃ ស. ស. ខ យើង បានផ្សាយឥទ្ធិពលដ៏ល្អជាទីគក់ក្ដៅ ដល់មិត្តសាស្ត្រាចារ្យឯទៀតៗ ដូចជាមិត្ត ឡឹក សំអ៊ូ និងមិត្តនារី តាន់ ធានី ដែលទើបនឹងសុំចូលជាសមាជិកថ្មី ជាហេតុធ្វើឲ្យចំនួនសមាជិកសមាគមយើងមកទល់នឹងថ្ងៃនេះ ឡើងដល់ ៧ ២១ នាក់ហើយ នៅក្នុងអនុវិទ្យាល័យទេពប្រណម្យ ៗ

● កាលពីថ្ងៃសុក្រ ទី ៧ មករា ១៩៦៦ ក្រោមការណែនាំនិងចាត់ចែងរបស់មិត្ត ឡុច សាវ៉ែម ចាងហ្វាងអនុវិទ្យាល័យ កូនចៅសម្ដេចឪ អង្គតាសោម ( តាកែវ ) មិត្តសមាជិកសមាគមយើង ព្រមទាំងបុគ្គលិកដទៃទៀតក្នុងសាលា បានធ្វើដំណើរតាមរថយន្តតាក់ស៊ីពីរគ្រឿងទៅភ្នំពេញ ដើម្បីសាកសួរកិរិយាលោក ជិន កែ អគ្គានុរក្សអនុវិទ្យាល័យដែលត្រូវវះនៅមន្ទីរពេទ្យមិត្តភាពខ្មែរ - សូវៀត ៗ ក្នុងពេលនោះ មិត្ត ឡុច សាវ៉ែមនៅបានប្រមូលវិភាគទានបាន ២៨០០រ ដើម្បីជួយសំរាលក្នុងការព្យាបាលជម្ងឺនេះទៀត ៗ

ចេញពីនេះ មិត្តយើងបាននាំគ្នាទៅសាកសួរកិរិយាមិត្ត សឹង ច័ន្ទ ដែលមានជម្ងឺលំបាកធ្ងន់ធ្ងរទៀត ដោយបានជួយវិភាគទាន ១១០០រ ផង ៗ ក្រោយមកទៀត យើងបានទទួលដំណឹងដោយរីករាយថា កាលពីថ្ងៃសុក្រទី ២៨ មករា ១៩៦៦ នៅមន្ទីរពេទ្យព្រះកេតុមាលា កិរិយាមិត្ត សឹង ច័ន្ទ បានសំរាលកូនប្រុសមួយដោយចាកផុតទុក្ខភ័យ ៗ

● យើងបានទទួលដំណឹងដោយក្រៀមក្រំថា កាលពីថ្ងៃ ២៥ ធ្នូ ១៩៦៥ បិតាមិត្ត អ៊ឹង អ៊ីកគាង បានទទួលអនិច្ចកម្ម នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ៗ មិត្តតំណាងនិងសមាជិក ស. ស. ខ ព្រមទាំងបុគ្គលិកទាំងអស់នៃវិទ្យាល័យព្រះគន្ធបុប្ផាយើង បានប្រមូលបច្ច័យខ្លះ ហើយបានចូលរួមរំលែកមរណទុក្ខរបស់មិត្តយើង ៗ

ពីចម្ងាយ សមាជិកគ.នាយកទាំងអស់ សូមមិត្ត អ៊ឹង អ៊ាកគាង ទទួលនូវការចូលរួមមរណទុក្ខនេះផង ។

ពីវិទ្យាល័យខាងលើនេះដែល យើងបានទទួលដំណឹងថា មិត្តតំណាង ស.ស.១ យើងបានចេញថវិកាផ្ទាល់ខ្លួន ទិញក្រូប ដើម្បីទៅសួរសុខទុក្ខរបស់ភរិយា មិត្ត ឈិម នឹម នាយកវិទ្យាល័យ ដែលសំរាលកូននៅមន្ទីរពេទ្យកំពង់ចាម ។ កាយវិការដូចគ្នានេះបានធ្វើចំពោះភរិយា មិត្ត វៀល មួន ដែលសំរាលកូននៅមន្ទីរពេទ្យនោះដែរ ។ មិនតែប៉ុណ្ណោះ មិត្តតំណាងយើងថែមទាំងបានទិញវត្ថុបន្តិចបន្តួច ទៅចងដៃកូនស្រី មិត្ត យិន គឹមតេក ទៀត ។

យើងសូមសរសើរនឹងប្រសិទ្ធិពរ ដល់មិត្តយើងទាំង ៣ ដែលទើបនឹងបានបុត្រថ្មី ៗ នេះ ហើយក៏សូមសំដែងសេចក្ដីពេញចិត្ត នឹងអំណរគុណចំពោះកាយវិការដ៏ប្រសើរនៃមិត្តតំណាង ស.ស.១ យើងប្រចាំវិទ្យាល័យព្រះគន្ធបុប្ផានេះដែរ ។

★

★ ★

## តារាងអក្សរខុស

| | | | | | |
|---|---|---|---|---|---|
| ទំព័រ | 13 | បន្ទាត់ | 7 | សូមអានថា : | s'explique... |
| | | — | 8 | — : | nationalistes... |
| | | — | 16 | — : | Il est... |
| — | 17 | — | 26..29 — | : | — Ouvrir = bœk ( en Khmer; dans ouvrir la porte, la fenêtre).<br>— Conduire = bœk ( mais d'un autre sens : conduire la voiture ) |
| | | — | 36 | — : | la voiture... |
| — | 70 - 71 : | | | | សូមអាន ជិនណែរ ជា យ៉ែន័រ ( Jenner ) |

# ស្ថានភាពហិរញ្ញវត្ថុ

*ចាប់ពីថ្ងៃ ១ មករា ១៩៦៦ រហូតមកដល់ថ្ងៃចេញទស្សនាវដ្ដីលេខ ២០ យើងបាន ទទួលភាគទានពីសាលានានា ដូចខាងក្រោមនេះ ៖*

| | | |
|---|---|---|
| វិទ្យាល័យ | ព្រះឧទ័យ ( តាកែវ ) | 1920 រៀល |
| — | សន្តិភាព ( កំពង់ស្ពឺ ) | 1670 — |
| — | ព្រះសុរិយោវង្ស | 931 — |
| — | ចៅពញាយ៉ាត ( ភ្នំពេញ ) | 560 — |
| — | ព្រះសីហនុ ( កំពង់ចាម ) | 2000 — |
| — | សុរិយាវរ្ម័នទី ២ ( សៀមរាប ) | 700 — |
| — | សង្គមរាស្ត្រនិយម ( ភ្នំពេញ ) | 1800 — |
| — | កំពង់ធំ | 1000 — |
| — | ឥន្ទ្រទេវី ( ភ្នំពេញ ) | 1700 — |
| — | ព្រះអង្គឌួង ( ព្រៃវែង ) | 1727 — |
| — | ព្រះស៊ីសុវត្ថិ | 1800 — |
| — | ព្រះគន្ធបុប្ផា ( កំពង់ចាម ) | 1055 — |
| អនុវិទ្យាល័យ | សាលាលេខប្រាំ ( កំពង់ឆ្នាំង ) | 310 + 200 — |
| — | រតនៈគិរី | 712 — |
| — | ពាមជីកង ( កំពង់ចាម ) | 500 + 560 — |
| — | ព្រៃដើមថ្នឹង ( ព្រៃវែង ) | 500 + 500 — |
| — | ស្ទឹងត្រង់ ( កំពង់ចាម ) | 426 + 386 — |
| — | ជើងឆ្នុក ( កំពង់ចាម ) | 1000 — |
| — | ស្គន់ ( កំពង់ចាម ) | 700 — |
| — | ជម្ពូវ័ន ( កណ្ដាល ) | 520 — |
| — | កូនចៅសម្ដេចឪ ( អង្គតាសោម ) | 540 — |
| — | ទេពប្រណម្យ ( កណ្ដាល ) | 743 — |
| — | នេតយ៉ង់ ( បាត់ដំបង ) | 500 — |

| | | |
|---|---|---|
| អនុវិទ្យាល័យ | ពារាំង (ព្រៃវែង) | 180 រៀល |
| — | ជ័យវរ្ម័នទី ៧ (កណ្ដាល) | 1200 — |
| — | សួង (កំពង់ចាម) | 3760 — |
| — | បញ្ជេកទេស (កំពង់ចាម) | 600 — |
| — | ស្ទឹ (កំពង់ចាម) | 600 — |
| — | ព្រះនរោត្តម (ភ្នំពេញ) | 1320 — |
| — | ស្ទឹងត្រែង | 1200 — |
| — | គីរីវង្ស (តាកែវ) | 1200 — |
| — | សិរីមង្គល (រការកោង) | 166 — |
| — | ព្រះសីហនុរាជ (ផ្សារថ្មី) | 960 — |
| — | ព្រែកតយ (កណ្ដាល) | 1100 — |
| — | កំពង់ក្ដី (សៀមរាប) | 440 — |
| — | កំពង់កន្ទួត (កណ្ដាល) | 300 — |
| — | ព្រែកពោធិ (កំពង់ចាម) | 540 — |
| ទីចាត់ការគរុកោសល្យ | | 360 — |
| មហាវិទ្យាល័យគរុកោសល្យ : | | |
| — | គណិតសាស្ត្រ ឆ្នាំទី ២ ក (ឆ្នាំទៅ) | 280 — |
| — | ប្រវត្តិសាស្ត្រ – ភូមិសាស្ត្រ | 100 — |
| — | ខ្មែរ ឆ្នាំទី ២ ១ | 1170 — |
| — | ខ្មែរ ឆ្នាំទី ២ ក | 300 — |
| — | ខ្មែរ ឆ្នាំទី ១ | 1200 — |
| — | គណិតសាស្ត្រ ឆ្នាំទី ២ ក | 880 — |
| — | គណិតសាស្ត្រ ឆ្នាំទី ២ ១ | 100 — |
| — | វិទ្យាសាស្ត្រធម្មជាតិ ឆ្នាំទី ២ ក | 300 — |
| — | បារាំង ឆ្នាំទី ២ ក | 170 — |
| — | រូបសាស្ត្រ ឆ្នាំទី ២ ក | 430 — |

គណៈកម្មាធិការនាយក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តជំពាក់ និងបាងហ្វាងសាលានានា ដែលបានចំប្រមូលភាគទាន ផ្ញើទៅសមាគម ។ នេះជាការលើកទឹកចិត្ត ឱយគ.នាយកមានកម្លាំងនឹងធ្វើការបំរើតទៅ។ ម្យ៉ាងទៀត គ.នាយក សូមអំពាវនាវ សមាជិកនៅសាលាដទៃទៀត សូមមេត្តាផ្ញើភាគទានទៅផង ដើម្បីជួយបេញថ្លៃបោះពុម្ពទស្សនាវដ្ដី នឹងរ៉ាប់មុខចំណាយផ្សេងៗ ឱយបានស្មើៗ នឹងសាលាខាងលើ ។ ជាពិសេស នៅសល់ខែត្រចិត : កំពត ពោធិសាត់ នឹងក្រចេះ ដែលយើងខ្ញុំពុំទាន់ទទួលអ្វីសោះនៅឡើយ ក្រៅពីបញ្ជីជំរឿន។សូមអរគុណជាមុន។

# មតិមិត្តយើង

មិត្ត គួច គីឡេង សាស្ត្រាចារ្យនៅវិទ្យាល័យព្រះស៊ីហនុ បានផ្ញើមកទស្សនាវដ្ដីយើងនូវសំបុត្រមួយ ថ្លែងយោបល់របស់មិត្តចំពោះបញ្ហាខេមរនីយកម្ម ដែលយើងសូមដកស្រង់នូវចំណុចសំខាន់ខ្លះដូចតទៅ :

“...គ្រប់ប្រទេស គេគិតជាតិគេមុន ៗ ជប៉ុនបង្រៀនជាជប៉ុន ចិនបង្រៀនជាចិន រុស្ស៊ីបង្រៀនជារុស្ស៊ី ភូមាបង្រៀនជាភូមា ឆេកូបង្រៀនជាឆេកូ អាល្លឺម៉ង់បង្រៀនជាអាល្លឺម៉ង់ បារាំងបង្រៀនជាបារាំង អង់គ្លេសបង្រៀនជាអង់គ្លេស ។ល។ ខ្ញុំមានយោបល់យល់ស្របទាំងស្រុងចំពោះមតិមិត្តសាស្ត្រាចារ្យយើង នៅអនុវិទ្យាល័យព្រះរាជបូជនីយកិច្ច ខេត្រស្ទឹង-ត្រែង ដែលយល់ច្បាស់នូវការលំបាកលំបិនរបស់សិស្សក្នុងការសិក្សា ហើយបានអនុមតិថា “ឯភាសាបារាំងទុកត្រឹមតែជាជីវភាសា (Langue vivante) ដូចជាភាសាអង់គ្លេសទៅវិញ” ( ទស្សនាវដ្ដីសាស្ត្រាចារ្យលេខ ៤/១៨, ខែមេសា - ឧសភា - មិថុនា, ឆ្នាំទី ៦, ទំព័រ៥៩ ) ដែលស្របនឹងការកែទម្រង់ថ្មី ដែលឯកឧត្តម ចៅ សេង បានឱ្យដឹងថា :

3— Adaptation du programme de français aux conditions des élèves khmers qui ne sont plus considérés comme des petits Français d'Indochine, mais comme des étrangers à la langue française. Pour cela, l'enseignement du français devient, dans le nouveau programme, simplement celui d'une langue vivante étrangère ( Kambuja, n° 3, 15 Juin 1965, page 69)... ”

# HUMOUR

## LE RIRE EST LE PROPRE DE L'HOMME

### Entendu dans une classe de Sciences physiques.

A la fin du cours, le professeur interroge :

— A quelle température l'eau bout-elle ?

— Un élève ( vraiment un «Beatles» ) : — Par ce que je sais, l'eau bout à 90° (il s'asseoit immédiatement ).

— Le professeur, un peu rougi, reprend d'une manière sèche : — à 90° ?

— L'élève :—Oh non pardon, c'est l'angle droit qui bout à 90°.

### La manie des définitions

Au cours d'une séance de français d'une classe de 5è, le professeur a l'habitude d'exiger des élèves une multitude de définitions pour contrôler si la leçon a été bien comprise :

— Qu'est-ce qu'un charpentier ?

— Un élève :— C'est celui qui fait des charpentes.

— Le professeur :— Bon ! Et qu'est-ce qu'un papayer ?

— Un autre élève ( brusquement retiré du sommeil d'Avril, et après quelques secondes de silence et d'hésitation ) :— C'est celui . . . . C'est celui qui fait des papa ( la classe devient bruyante ... et le professeur ferme son livre sans rien dire; puis regardant par la fenêtre , il montre un papayer situé à côté de la salle de classe ).

— Plusieurs élèves font entendre simultanément :— «Eup ! j'ai cru que c'est...... Et s'il a fait cela depuis longtemps ! »

### Qu'est - ce que l'homme ?

Platon avait appelé l'homme : « un animal à deux pieds qui n'a pas de plumes ».

Diogène ( Apollonie ) plume un coq et dit : « Voilà donc l'homme de Platon ! ».

**Molière et les médecins**

Tout le monde, sauf peut-être ADAM et EVE, sait que l'auteur du « Malade imaginaire » n'est pas tendre pour les successeurs d'Hippocrate.

Un jour, que son ami lui demande comment sent-il avec son médecin, Molière se contente de dire simplement : « il me donne des remèdes quand je suis malade, je ne les prends point et JE GUÉRIS ».

**Histoire corse**

Il y a des manières de dormir : dormir debout, dormir à genoux, dormir sur-le-champ. Une nuit, dans un village de haute montagne, on entend :

— Hé, Nico, fait le voisin, tu dors, oui ou non ?

— Ça dépend ( répond Nico ), et qu'est - ce qu'il y a ?

— Tu peux me prêter ton âne ?

— Je dors.

**Déjà un signe de courage, de sang - froid**

Après avoir longtemps écouté Lloyd-George («le bouillant Lloyd-George ») à la chambre des communes, un député - dame de l'opposition s'est écrié :

— Si vous êtes mon mari, je vous ferai boire du poison.

— Madame, si je suis votre mari, je me donnerai du courage de l'avaler.

**Encore des définitions !**

Q.— Qu'est-ce qu'un tigre ?

R.— C'est un chat majuscule.

Q.— Qu'est-ce qu'un marin bigame ?

R.— C'est celui qui a deux femmes à chaque port.

Q.— Qu'est-ce qu'un abeille ?

R.— C'est une mouche à miel.

KLPHON

# ការប្រឡងចូលមហាវិទ្យាល័យគរុកោសល្យ

យើងទើបនឹងបានទទួលសេចក្ដីចំលងមួយច្បាប់នៃលិខិតរបស់មិត្តសាស្ត្រាចារ្យ ជាគ្រូបឋមសិក្សាបំពេញ-វិជ្ជា ចំនួន ២៣ នាក់ ដែលផ្ញើមកពីក្រចេះ ។ គឺជាលិខិតផ្ញើទៅថ្វាយអ្នកអគ្គម្ចាស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងអប់រំជាតិ ដើម្បីស្នើសុំសេចក្ដីអនុគ្រោះ ពីក្រសួងអប់រំជាតិ ឲ្យទុកសិទ្ធិប្រឡងចូលមហាវិ.គរុកោសល្យ ដល់លោកគ្រូដែលមានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ( D. E. S. P. C. ) ហើយដែលបានបំរើសិក្សាធិការជាតិ បាន ៣ ឆ្នាំហើយ ។

ចំពោះយើងវិញ យើងយល់ថា ការទុកសិទ្ធិប្រឡងឲយលោកគ្រូបឋមសិក្សាបំពេញវិជ្ជា ទោះកន្លែងទុកឲយនោះតិចក្ដី ច្រើនក្ដី គឺជាការកម្សាន្តចិត្តមួយចំពោះមិត្តយើង ជាការនាំឲយមិត្តយើងនៅតែមានសេចក្ដីសង្ឃឹមនឹងព្យាយាមរៀនសូត្រ ព្យាយាមបង្កើនចំណេះចេះដឹងរបស់ខ្លួន ជាហេតុធ្វើឲយកិច្ចការបង្រៀនរបស់មិត្តកាន់តែបានលទ្ធផលល្អ ៗ ហើយក៏ធ្វើឲយប្រទេសជាតិ កាន់តែសំបូរអ្នកចេះដឹងជ្រៅជ្រះឡើង ៗ ដែរ ។

ហេតុនេះហើយបានជាយើងយល់ស្រប នឹងឧបត្ថម្ភទាំងអស់នូវសំណូមនៃមិត្តទាំង ២៣ រូប ហើយសូមចុះផ្សាយសេចក្ដីនៃលិខិតនេះទាំងស្រុងដូចតទៅ :

*ក្រចេះ ថ្ងៃទី ១ មេសា គ.ស. ១៩៦៦*

*សូមក្រាបបង្គំទូលមក អ្នកអគ្គម្ចាស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងអប់រំជាតិ*

*នៅក្រុងភ្នំពេញ សូមទ្រង់ជ្រាប ។*

*តាមរយៈនៃលោកនាយកមធ្យមសិក្សា*

*តាមរយៈនៃលោកនាយកវិទ្យាល័យ ព្រះមហាក្សត្រិយានី កុសុមៈ ក្រចេះ*

*ទូលបង្គំទាំងឡាយដូចមានរាយនាម នឹងចុះហត្ថលេខាខាងក្រោមនេះ សូមក្រាបបង្គំដោយគោរព ទូលស្នើចំពោះអ្នកអគ្គម្ចាស់ទេសរដ្ឋមន្ត្រី អំពីការសូមសេចក្ដីអនុគ្រោះ ទុកសិទ្ធិឲយប្រឡងប្រជែងយកកន្លែងរៀនជានិស្សិតសាស្ត្រាចារ្យ សម្រាប់គ្រូបង្រៀនបឋមសិក្សាបំពេញវិជ្ជា មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ដូចខាងក្រោមនេះ :*

តាមសេចក្ដីសម្រេចនៃសន្និសីទការងារមួយ ដែលបានធ្វើនៅភ្នំពេញ ក្នុងពេលថ្មីៗនេះ គ្រូបង្រៀនបឋមសិក្សាបំពេញវិជ្ជាទាំងឡាយ ដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ហើយដែលបានធ្វើការបំរើមុខក្រសួងកំណត់កាលហើយនោះ បានត្រូវឲ្យអស់សិទ្ធិប្រឡងប្រដែងចូលរៀន ជានិស្សិតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិតទៅទៀត ។ ការសម្រេចលុបសិទ្ធិនេះ បាននាំឲ្យទូលបង្គំទាំងឡាយ ជាគ្រូបង្រៀនបឋមសិក្សាបំពេញវិជ្ជា បានបំពេញលក្ខណៈច្បាប់គ្រប់គ្រាន់ ហើយបានយកចិត្តរៀនសូត្រទាំងយប់ថ្ងៃក្រៅពេលធ្វើការ ដើម្បីសម្រិតសម្រាំងវប្បធម៌ទៅក្នុងវិជ្ជាជីវៈរបស់ខ្លួន ឲ្យមានកម្រិតខ្ពស់ជាលំដាប់តទៅនោះ មានការស្រងាកចិត្តខ្លាំងពន់ពេក ពីព្រោះ

១ មួយ– ទូលបង្គំទាំងឡាយ នឹងអស់មានអនាគតក្ដីស្ថានតាមលំដាប់ សមតាមបំណងរបស់ខ្លួន ដែលមានមនសិការចង់លូតលាស់ខាងសមត្ថភាពជានិច្ច តាមភាពនៃខ្លួនជាអ្នកបំរើក្រសួងបច្ចេកទេសមួយ មានការៈសម្រិតសម្រាំងវិជ្ជាអប់រំយុវជនតទៅ តាមកាលសម័យ ។

១ ពីរ– ពិតមែនហើយថា ប្រទេសយើងសំបូណ៌ដោយយុវជន ដែលមានមធ្យមសិក្សាប័ត្រភាគទី ១ នឹងទី ២ តម្រូវឲ្យរាជការមានសមត្ថកិច្ចអនុគ្រោះរកកន្លែងការងារឲ្យធ្វើ ទូលបង្គំទាំងឡាយ ដែលមានវិជ្ជាជីវៈរួចទៅហើយនោះ ក៏ពុំមានបំណងជ្រៀតជ្រែកដណ្ដើមយកសុខតែឯងឡើយ ប៉ុន្តែការលុបសិទ្ធិផ្ដាច់យ៉ាងនេះ ក៏សន្មតថារាជការមានសមត្ថកិច្ចលែងមេត្តាអនុគ្រោះ ដល់អ្នករាជការចាស់ដែលមានមនសិការមិនឈប់ឈរក្នុងវិជ្ជាជីវៈ នឹងដែលគួរតែបានទទួលផលខ្ពស់ជាលំដាប់តទៅ ដូចជាភ្នាក់ងាររាជការក្នុងក្រុមខណ្ឌឯទៀតៗ មានមន្ត្រីសុខាភិបាលជាដើម ដែលមានសិទ្ធិចូលរៀនយកថ្នាក់វេជ្ជបណ្ឌិតបាន ដោយពុំមានខូចខាតផលប្រយោជន៍អ្វីបន្តិច មានការបើកបៀវត្សបានដូចធម្មតាជាដើម ។

សេចក្ដីដូចក្រាបបង្គំទូលមកនេះ ទូលបង្គំទាំងឡាយ សូមក្រាបបង្គំទូលស្នើអ្នកអង្គម្ចាស់ សូមធ្វើសំណូមពរ ដូចខាងក្រោមនេះ :

១ មួយ– សូមរាជរដ្ឋាភិបាលមេត្តាអនុគ្រោះទុកសិទ្ធិប្រឡងប្រជែងនេះ ឲ្យនៅដដែល ទោះបីអនុគ្រោះឲ្យកន្លែងស្ដួចស្ដើងប៉ុណ្ណាក៏ដោយ ។

១ ពីរ– សូមរាជរដ្ឋាភិបាល មេត្តាអនុគ្រោះដល់គ្រូបង្រៀនចាស់ទាំងនោះ ដែលបានទទួលសិទ្ធិចូលប្រឡងប្រជែងហើយជាប់ជានិស្សិតសាស្ត្រាចារ្យហើយនោះ មានសិទ្ធិទទួលបៀវត្សដូចធម្មតារបស់ខ្លួនកាលនៅធ្វើការ ដើម្បីអាចចិញ្ចឹមគ្រួសារដែលមានបន្ទុកច្រើន ហើយទូលបង្គំទាំងឡាយសូមសន្យាថា នឹងស្ម័គ្រចិត្តបំរើកិច្ចការមុខក្រសួង ឲ្យមានលក្ខណៈលើសពីនិស្សិតធម្មតា នៅពេលចន្លោះការរៀនសូត្រ បើរាជការត្រូវការ ។

សេចក្ដីដូចបានក្រាបបង្គំទូលស្នើមកនេះ ទូលបង្គំទាំងឡាយសូមអ្នកអង្គម្ចាស់ទេសរដ្ឋមន្ត្រី មេត្តាសព្វព្រះហឫទ័យអនុគ្រោះ តាមដែលទ្រង់អាចសម្រេចទៅបានដល់សេចក្ដីស្នើនេះដោយក្រោសប្រណី ។

សេចក្ដីគួរពុំគួរសូមទ្រង់មេត្តាប្រោស

**បណ្ណាគារ វិជ្ជាធិពូ**

លេខ 524 វិថីកម្ពុជាក្រោម ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃ 15 % ជូនសមាជិក សមាគមសាស្ត្រាចារ្យខ្មែរ ដែលទៅទិញសៀវភៅខ្មែរ ហើយដែលបង្ហាញបណ្ណសមាជិក ។

បានតម្កល់ទុកតាមច្បាប់ត្រឹមត្រូវ
អនុញ្ញាតលេខ ១០៧ ចុះថ្ងៃទី ២៧ – ២ – ៦៦
បោះពុម្ពលើកទី ២ ចំនួន ១.៤០០ ក្បាល ។




លេខ ៦៩ វិថីខេមរភូមិន្ទ ភ្នំពេញ

បើមិត្តសមាជិក ស. ស. ខ. កាន់ប័ណ្ណ សមាជិកទៅទិញខោអាវនៅហាងនេះ ហាងនេះ មានសេចក្ដីរីករាយ ហើយនឹងកិត្តិយសនឹងចុះថ្លៃជូនមិត្តយ៉ាងពេញចិត្ត ។

សូមអញ្ជើញសាកមើល !